# អនុសញ្ញាស្តីពីសិទ្ធិកុមារ



ផលិតនិងរៀបរៀងដោយ

មូលនិធិសិទ្ធិកុមារ
Child Rights Foundation

ឧបត្ថម្ភដោយ

Plan
Be a part of it.

ផលិតនៅខែធ្នូ ឆ្នាំ២០០៥

**កែប្រែសម្រួលនិងរៀបរៀង :** លោក វ៉ែន កុយ ប្រធានកម្មវិធី មូលនិធិសិទ្ធិកុមារ
**អ្នករចនាកុំព្យូទ័រ :** លោក ទី សុវណ្ណារី មន្ត្រីគម្រោង មូលនិធិសិទ្ធិកុមារ
**អ្នកត្រួតពិនិត្យ :** លោកស្រី ម៉ុម ថានី នាយិកាប្រតិបត្តិ មូលនិធិសិទ្ធិកុមារ

**អាសយដ្ឋានមូលនិធិសិទ្ធិកុមារ**
ផ្ទះលេខ២៩អឺ១ មហាវិថីម៉ៅសេទុង សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (៨៥៥) ០២៣ ២១១ ២២៣ អ៊ីមែល: crf2002@online.com.kh

# មាតិកា


| | |
|---|---|
| គោលការណ៍ទូទៅនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ | ១ |
| សិទ្ធិ និងសេរីភាពរបស់កុមារ | ៧ |
| សិទ្ធិកុមារ និងក្រុមគ្រួសារ | ១៥ |
| សិទ្ធិរបស់កុមារក្នុងការទទួលបាននូវការថែទាំសុខភាព មូលដ្ឋាន និងសុខុមាលភាព | ២៤ |
| សិទ្ធិរបស់កុមារក្នុងការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌ | ២៩ |
| សិទ្ធិរបស់កុមារក្នុងការទទួលបាននូវការការពារពិសេស | ៣៣ |
| ខ្លឹមសារពិស្តារនៃមាត្រាទាំង៥៤នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ | ៣៨ |

# អនុសញ្ញាស្តីពីសិទ្ធិកុមារ

# គោលការណ៍ទូទៅនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ



កុមារ គឺជាមនុស្សដែលមានអាយុក្រោម១៨ឆ្នាំ។

(មាត្រា ១)



កុមារមិនត្រូវទទួលរងនូវការរើសអើងឡើយ ទោះបីកុមារនោះ ឬឪពុកម្ដាយ ឬអ្នកអាណាព្យាបាល មានពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយឬទស្សនៈផ្សេងៗ សញ្ជាតិ ជនជាតិ ទ្រព្យសម្បត្តិ ពិការភាព និងស្ថានភាពកំណើតផ្សេងៗពីគ្នាក៏ដោយ។

(មាត្រា ២)



រាល់សេចក្ដីសម្រេចចិត្ត ឬសកម្មភាពពាក់ព័ន្ធនឹងកុមារដែលធ្វើឡើង ដោយរដ្ឋាភិបាល ផ្នែករដ្ឋបាល ឬអាជ្ញាធរមូលដ្ឋាន ឬដោយក្រុមគ្រួសារ កុមារផ្ទាល់ត្រូវគិតគូរដល់ឧត្ដមប្រយោជន៍របស់កុមារ។

(មាត្រា ៣)



កុមារមានសិទ្ធិរស់រានមានជីវិតនិងសិទ្ធិអភិវឌ្ឍន៍លើគ្រប់ផ្នែក រួមទាំងផ្នែករូបរាងកាយ អារម្មណ៍ សីលធម៌ បញ្ញាស្មារតី សង្គម និងវប្បធម៌។

(មាត្រា ៦)




កុមារត្រូវតែទទួលបាននូវការអនុញ្ញាតឱ្យចូលរួមដោះស្រាយរាល់បញ្ហាដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ និងសម្ដែងមតិរបស់គេដោយសេរី។ កុមារមានសិទ្ធិធ្វើឱ្យទស្សនៈរបស់ខ្លួនត្រូវបានស្ដាប់ហើយអ្នកពាក់ព័ន្ធទាំងឡាយត្រូវតែយកទស្សនៈទាំងនេះមកពិចារណាឱ្យបានហ្មត់ចត់។

(មាត្រា ១២)

# សិទ្ធិ និងសេរីភាពរបស់កុមារ




កុមារគ្រប់រូបមានសិទ្ធិមានឈ្មោះមួយ និងសញ្ជាតិមួយ។

(មាត្រា ៧)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារ
ពីការដកហូតអត្តសញ្ញាណរបស់ខ្លួន។

(មាត្រា ៨)




កុមារគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការសម្តែងមតិ។

(មាត្រា ១៣)




កុមារគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការគិត
ក្នុងការមានមនសិការ និងជ្រើសរើសសាសនា។

(មាត្រា ១៤)



កុមារគ្រប់រូបមានសិទ្ធិសេរីភាព
ក្នុងការបង្កើតសមាគម និងជួបជុំគ្នាដោយសន្តិវិធី។

(មាត្រា ១៥)



កុមារគ្រប់រូបមានសិទ្ធិការពារពីការជ្រៀតជ្រែករឿងជីវិតឯកជនរបស់គេ។

(មាត្រា ១៦)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវព័ត៌មានពីប្រភពផ្សេងៗ។

(មាត្រា ១៧)

# សិទ្ធិកុមារ និង ក្រុមគ្រួសារ



រដ្ឋាភិបាលត្រូវធានាសិទ្ធិរបស់ឪពុកម្តាយ
និងក្រុមគ្រួសារ ក្នុងការអប់រំណែនាំកូន។

(មាត្រា ៥)



កុមារគ្រប់រូបមានសិទ្ធិរស់នៅជាមួយឪពុកម្តាយរបស់ខ្លួន ឬរក្សាទំនាក់ទំនងជាមួយឪពុក ឬម្តាយ ក្នុងករណីដែលខ្លួនត្រូវបែកពីអ្នកណាម្នាក់។

(មាត្រា ៩)




កុមារគ្រប់រូបមានសិទ្ធិឆ្លងដែនពីប្រទេសមួយ
ទៅប្រទេសមួយទៀត ដើម្បីជួបជុំជាមួយឪពុកម្តាយឡើងវិញ។

(មាត្រា ១០)



រដ្ឋាភិបាលត្រូវគាំទ្រឪពុកម្តាយក្នុងការចិញ្ចឹមកូន និងទទួលស្គាល់ថា ឪពុកម្តាយមានការទទួលខុសត្រូវរួមគ្នាក្នុងការចិញ្ចឹមបីបាច់បុត្រធីតា។

(មាត្រា ១៨ កថាខ័ណ្ឌ ១ និង ២)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការថែទាំជំនួស
នៅពេលដែលបរិយាកាសគ្រួសារមិនអាចរក្សាបាន។

(មាត្រា ២០)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវប្រព័ន្ធសុំកូនចិញ្ចឹម
ដែលមានសុវត្ថិភាព។

(មាត្រា ២១)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការត្រួតពិនិត្យ
កន្លែងស្នាក់នៅជាទៀងទាត់ ដែលជាការចាំបាច់ក្នុងការ
ត្រួតពិនិត្យមើលលើការថែទាំ ការការពារ ឬការប្រព្រឹត្តផ្សេងៗ។

(មាត្រា ២៥)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារ
ពីការរំលោភបំពាន និងភាពមិនអើពើពីឪពុកម្តាយ ឬអ្នកថែទាំ
និងមានសិទ្ធិទទួលបាននូវការធានាការដោះស្រាយសមស្រប
ដើម្បីឱ្យពួកគេអាចស្តារលទ្ធភាព និងរួមរស់នៅក្នុងសង្គមជាតិវិញ។

(មាត្រា ១៩ និង ៣៩)



# សិទ្ធិរបស់កុមារក្នុងការទទួលបាននូវការថែទាំ សុខភាពមូលដ្ឋាន និងសុខុមាលភាព



កុមារពិការគ្រប់រូបមានសិទ្ធិទទួលបាន
នូវការថែទាំពិសេស ដើម្បីធានានូវសេចក្តីថ្លៃថ្នូរ ជួយឱ្យមានភាព
ម្ចាស់ការ និងជួយសម្រួលឱ្យមានការចូលរួមយ៉ាងសកម្មក្នុងសហគមន៍។

(មាត្រា ២៣)




កុមារគ្រប់រូបមានសិទ្ធិទទួលបាន
នូវការថែទាំសុខភាពដែលមានគុណភាពកម្រិតខ្ពស់បំផុត
ដែលអាចធ្វើបាន និងសេវាសុខភាពប្រកបដោយប្រសិទ្ធភាព។

(មាត្រា ២៤)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវសន្តិសុខសង្គម និងសេវាថែទាំកុមារ
និងភាពងាយស្រួលក្នុងការទទួលបានសេវាទាំងនោះ។

(មាត្រា ២៦ និង ១៨ កថាខ័ណ្ឌ ៣)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការរស់នៅក្នុងកម្រិតជីវភាពមួយ
ដែលសមស្រប។

(មាត្រា ២៧)



# សិទ្ធិរបស់កុមារក្នុងការអប់រំ ការលំហែ និង សកម្មភាពវប្បធម៌



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការអប់រំ
កម្រិតបឋមសិក្សាដោយឥតបង់ថ្លៃ មានសិទ្ធិទទួលការ
អប់រំនៅមធ្យមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

(មាត្រា ២៨)



កុមារគ្រប់រូបមានសិទ្ធិទទួលការអប់រំដែលធានាដល់ការអភិវឌ្ឍបុគ្គលិក
លក្ខណៈ ទេពកោសល្យ រាងកាយ បញ្ញាស្មារតី និងធានាឱ្យកុមារក្លាយ
ជាពលរដ្ឋដែលមានការទទួលខុសត្រូវក្នុងសង្គមប្រជាធិបតេយ្យ
ចេះយោគយល់គ្នា គោរពសិទ្ធិមនុស្ស វប្បធម៌ ភាសានិងតម្លៃរបស់ជាតិ។

(មាត្រា ២៩)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការលំហែ
ការលេងកម្សាន្ត និងឱកាសចូលរួមក្នុងសកម្មភាព វប្បធម៌ និង សិល្បៈ។

(មាត្រា ៣១)



# សិទ្ធិរបស់កុមារក្នុងការទទួលបាននូវ ការការពារពិសេស



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារពិសេស
ក្នុងស្ថានភាពមានអាសន្ន ដូចជាពេលមានជម្លោះប្រដាប់អាវុធ
ឬនៅពេលដែលកុមារត្រូវបានបំបែកចេញពីក្រុមគ្រួសារ ឬចេញពីផ្ទះ។

(មាត្រា ២២ ៣៨ និង ៣៩)




កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារពិសេស
នៅពេលដែលកុមារនោះមានបញ្ហាជាមួយនឹងច្បាប់។

(មាត្រា ៤០ និង ៣៧ កថាខ័ណ្ឌ ខ គ និង ឃ)



កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារពិសេសពី
ពលកម្មកុមារ ការប្រើគ្រឿងញៀន ការកេងប្រវ័ញ្ចផ្លូវភេទ
ឬការរំលោភផ្លូវភេទ ការលក់ ការជួញដូរ និងការចាប់ពង្រត់។

(មាត្រា ៣២ ៣៣ ៣៤ និង ៣៥)



កុមារនៃសហគមន៍ជនជាតិភាគតិច និងកុមារនៃជនជាតិដើម
មានសិទ្ធិទទួលបាននូវការសប្បាយរីករាយជាមួយវប្បធម៌របស់គេ
និង មានសិទ្ធិប្រតិបត្តិនូវសាសនា និងភាសារបស់គេផ្ទាល់។

(មាត្រា ៣០)

# ខ្លឹមសារពិស្តារនៃមាត្រានាំង៥៤នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

*(អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩*
*និងផ្តល់សច្ចាប័នដោយព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២)*

## ផ្នែកទី ១

### មាត្រា ១

ជាគោលដៅនៃអនុសញ្ញានេះ កុមារមានន័យថាមនុស្សគ្រប់រូបដែលមានអាយុតិចជាងដប់ប្រាំបីឆ្នាំ លើកលែងតែអាយុពេញវ័យត្រូវបានគេសន្មតរហ័សជាងនេះ ដោយអនុលោមទៅតាមច្បាប់សម្រាប់អនុវត្តចំពោះកុមារ។

### មាត្រា ២

១. រដ្ឋជាភាគីត្រូវគោរពនិងធានានូវសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ ចំពោះរាល់កុមារដែលស្ថិតនៅក្នុងដែនអំណាចច្បាប់របស់ខ្លួន ដោយគ្មានការរើសអើងអ្វីទាំងអស់លើផ្នែកពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយឬទស្សនៈផ្សេងៗ សញ្ជាតិ ប្រភពសាសនាឬប្រភពសង្គម ទ្រព្យសម្បត្តិ ពិការភាព ស្ថានភាពកំណើត ឬស្ថានភាពអ្វីផ្សេងៗទៀតរបស់កុមារ ឬរបស់ឪពុកម្តាយកុមារ ឬរបស់អ្នកអាណាព្យាបាលស្របច្បាប់របស់កុមារឡើយ។

២. រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងឡាយ ដើម្បីធានាថា កុមារត្រូវបានការពារតទល់នឹងរាល់ទម្រង់នៃការរើសអើង ឬការដាក់ទណ្ឌកម្ម ដោយផ្អែកលើស្ថានភាព សកម្មភាព ការបញ្ចេញមតិ ឬជំនឿរបស់ឪពុកម្តាយ អ្នកអាណាព្យាបាលស្របច្បាប់ ឬសមាជិកនានានៃក្រុមគ្រួសាររបស់កុមារ។

## មាត្រា ៣

១. នៅក្នុងសកម្មភាពទាំងអស់ដែលទាក់ទិននឹងកុមារ ទោះជាសកម្មភាពនោះអនុវត្តដោយស្ថាប័នសង្គមកិច្ចសាធារណៈឬឯកជន ដោយតុលាការ ដោយអាជ្ញាធររដ្ឋបាល ឬដោយស្ថាប័ននីតិបញ្ញត្តិក្តី គឺត្រូវតែគិតគូរជាចម្បងដល់ផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់កុមារ ។

២. រដ្ឋជាភាគីសន្យាថានឹងធានាដល់កុមារនូវកិច្ចការពារនិងការថែទាំទាំងឡាយដែលចាំបាច់សម្រាប់សុខភាពរបស់កុមារ ដោយគិតគូរដល់សិទ្ធិនិងករណីយកិច្ចរបស់ឪពុកម្តាយ អ្នកអាណាព្យាបាលស្របច្បាប់ ឬបុគ្គលឯទៀតដែលទទួលខុសត្រូវស្របច្បាប់លើកុមារ ហើយក្នុងទិសដៅនេះ ត្រូវប្រកាន់យកនូវរាល់វិធានការផ្នែកច្បាប់ និងផ្នែករដ្ឋបាលទាំងឡាយដែលសមស្រប ។

៣. រដ្ឋជាភាគីត្រូវធានាថា ស្ថាប័ននានា សេវាកម្មផ្សេងៗ និងមធ្យោបាយទាំងឡាយសម្រាប់ថែទាំ ឬការពារកុមារ ត្រូវមានលក្ខណៈត្រឹមត្រូវ ស្របទៅតាមបទដ្ឋានដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ជាពិសេសខាងសុវត្ថិភាព សុខភាព ចំនួនបុគ្គលិកនិងលក្ខណៈសម្បត្តិបុគ្គលិកនៃស្ថាប័នទាំងនោះ ព្រមទាំងគុណភាពនៃការគ្រប់គ្រង ។

## មាត្រា ៤

រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ទាំងផ្នែកច្បាប់ ផ្នែករដ្ឋបាល និងផ្នែកផ្សេងទៀត ដើម្បីអនុវត្តសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ ចំពោះសិទ្ធិដែលទាក់ទងនឹងផ្នែកសេដ្ឋកិច្ច ផ្នែកសង្គម និងផ្នែកវប្បធម៌ រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការអស់ទាំងនោះក្នុងកម្រិតអតិបរមានៃប្រភពធនធានដែលខ្លួនមាន ហើយបើសិនជាចាំបាច់ ត្រូវស្វែងរកធនធានក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

## មាត្រា ៥

រដ្ឋជាភាគីត្រូវគោរពដល់ការទទួលខុសត្រូវ គោរពសិទ្ធិ និងគោរពករណីយកិច្ចរបស់ឪពុកម្តាយ ឬរបស់អ្នកអាណាព្យាបាលស្របច្បាប់ ដែលជាសមាជិកគ្រួសារជាសាច់ញាតិឆ្ងាយៗ ឬសមាជិកនៃសហគមន៍ដែលគេផ្តល់សិទ្ធិឱ្យតាមទំនៀមទម្លាប់ប្រចាំភូមិស្រុក (ប្រសិនបើមាន) ឬអ្នកផ្សេងៗទៀត

ដែលទទួលខុសត្រូវតាមផ្លូវច្បាប់លើកុមារ ក្នុងការផ្តល់ដល់កុមារទៅតាមរបៀបមួយដែលស៊ីគ្នាទៅនឹងការចម្រើនលូតលាស់នៃសមត្ថភាពរបស់កុមារនូវការដឹកនាំនិងការផ្តល់ដំបូន្មានសមស្របទៅនឹងការប្រើប្រាស់សិទ្ធិទាំងឡាយដែលទទួលស្គាល់ដោយអនុសញ្ញានេះ ។

## មាត្រា ៦

១. រដ្ឋជាភាគីទទួលស្គាល់ថា កុមារគ្រប់រូបមានសិទ្ធិដែលមិនអាចដកហូតបានក្នុងការមានជីវិត ។

២. រដ្ឋជាភាគីត្រូវធានាដល់ការរស់នៅ ព្រមទាំងការអភិវឌ្ឍរបស់កុមារឱ្យបានដល់កម្រិតខ្ពស់បំផុត ។

## មាត្រា ៧

១. កុមារត្រូវបានចុះបញ្ជីកំណើតភ្លាមក្រោយពេលប្រសូត្រមកហើយមានសិទ្ធិក្នុងការមានឈ្មោះមួយ មានសិទ្ធិទទួលបានសញ្ជាតិមួយតាំងពីពេលកើតមកភ្លាម និងមានសិទ្ធិស្គាល់ឪពុកម្តាយខ្លួន ព្រមទាំងទទួលបានការថែទាំពីអ្នកទាំងនោះឱ្យបានពេញលេញបរិបូរណ៍តាមតែអាចធ្វើទៅកើត ។

២. រដ្ឋជាភាគីត្រូវធានាដល់ការអនុវត្តសិទ្ធិទាំងនេះ ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន និងអនុលោមទៅតាមកាតព្វកិច្ចទាំងឡាយរបស់ខ្លួនដែលមានចែងនៅក្នុងឯកសារអន្តរជាតិនានាដែលពាក់ព័ន្ធក្នុងរឿងនេះ ជាពិសេសនៅទីកន្លែងណាដែលកុមារពុំទាន់មានឯកសារទាំងនេះ ។

## មាត្រា ៨

១. រដ្ឋជាភាគីសន្យាថា គោរពដល់សិទ្ធិរបស់កុមារក្នុងការរក្សាទុកនូវអត្តសញ្ញាណរបស់ខ្លួន ដោយរាប់បញ្ចូលទាំងសញ្ជាតិ ឈ្មោះ ព្រមទាំងទំនាក់ទំនងគ្រួសារ ដូចដែលទទួលស្គាល់តាមផ្លូវច្បាប់ ដោយគ្មានការលូកជ្រៀតជ្រែកចូលដោយខុសច្បាប់ឡើយ ។

២. នៅពេលដែលកុមារត្រូវបានដកហូតដោយខុសច្បាប់នូវធាតុណាមួយ ឬក៏ទាំងស្រុងនៃអត្តសញ្ញាណរបស់ខ្លួន រដ្ឋជាភាគីត្រូវផ្តល់នូវកិច្ចការពារ និងជំនួយឧបត្ថម្ភឱ្យបានសមស្រប ដើម្បីធ្វើអត្តសញ្ញាណនេះឡើងវិញយ៉ាងឆាប់រហ័ស ។

## មាត្រា ៩

១. រដ្ឋជាភាគីត្រូវធានាថា កុមារមិនត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ខ្លួន ដោយផ្ទុយពីឆន្ទៈកុមារឡើយ លើកលែងតែអាជ្ញាធរមានសមត្ថកិច្ចកំណត់តាមច្បាប់និងនីតិវិធីដែលអាចអនុវត្តបានថា ករណីបំបែកនេះគឺជាការចាំបាច់សម្រាប់ផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់កុមារ ។ ការកំណត់នេះត្រូវធ្វើក្នុងលក្ខខណ្ឌដែលត្រូវមានការពិនិត្យឡើងវិញផ្នែកផ្លូវច្បាប់ ។ ការកំណត់បែបនេះអាចជាការចាំបាច់នៅក្នុងករណីពិសេសណាមួយ ដូចជាករណីដែលឪពុកម្តាយរំលោភបំពានឬមិនគិតគូរដល់កុមារ ឬក្នុងករណីដែលឪពុកម្តាយរស់នៅបែកគ្នាហើយទាមទារឱ្យមានការសម្រេចពីទីកន្លែងដែលកុមារត្រូវស្នាក់នៅ ។

២. នៅក្នុងរាល់កិច្ចពិភាក្សាទាក់ទិននឹងកថាខ័ណ្ឌ១នៃមាត្រានេះ ត្រូវអនុញ្ញាតឱ្យគ្រប់ភាគីទាំងអស់ដែលមានការទាក់ទងក្នុងរឿងនេះ ចូលរួមនៅក្នុងកិច្ចពិភាក្សា ដើម្បីបញ្ចេញមតិយោបល់របស់ខ្លួន ។

៣. រដ្ឋជាភាគីត្រូវគោរពសិទ្ធិរបស់កុមារដែលត្រូវបានបំបែកចេញពីឪពុកឬពីម្តាយ ឬបំបែកចេញពីអ្នកទាំងពីរ ក្នុងការរក្សាទំនាក់ទំនងជាលក្ខណៈបុគ្គលនិងដោយផ្ទាល់ជាមួយឪពុកម្តាយឱ្យបានទៀងទាត់ លើកលែងតែប្រការនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់កុមារ ។

៤. នៅពេលដែលការបំបែកពីគ្នានេះបណ្តាលមកពីសកម្មភាពរបស់រដ្ឋជាភាគី ដូចជាការឃាត់ខ្លួន ការដាក់ពន្ធនាគារ ការនិរទេស ការបំបរបង់ ឬមរណភាព(រួមទាំងមរណភាពដែលបណ្តាលមកពីមូលហេតុអ្វីក៏ដោយក្នុងអំឡុងពេលដែលបុគ្គលនោះស្ថិតនៅកន្លែងឃាត់ខ្លួនរបស់រដ្ឋ) របស់អ្នកណាម្នាក់ជាឪពុកឬជាម្តាយ ឬក៏ទាំងឪពុកទាំងម្តាយ ឬក៏របស់កុមារ ពេលមានសំណើសុំ រដ្ឋជាភាគីត្រូវតែផ្តល់ដល់ឪពុកម្តាយ ដល់កុមារ ឬប្រសិនបើមានដល់សមាជិកផ្សេងទៀតនៃគ្រួសារ នូវព័ត៌មានសំខាន់ៗទាក់ទិនទៅនឹងទីកន្លែងនៃសមាជិកគ្រួសារដែលបាត់បង់ លើកលែងតែការផ្តល់ព័ត៌មាននោះអាចធ្វើឱ្យប៉ះពាល់ដល់សុខុមាល

ភាពរបស់កុមារ ។ម្យ៉ាងទៀតរដ្ឋជាភាគីត្រូវធានាថា ការដាក់សំណើសុំបែបនេះ នឹងមិននាំជាផលវិបាកអាក្រក់អ្វីដល់សាមីជនដែលទាក់ទិននោះឡើយ ។

## មាត្រា ១០

១. អនុលោមតាមកាតព្វកិច្ចរបស់រដ្ឋជាភាគីដែលមាននៅក្នុងមាត្រា៩ កថាខ័ណ្ឌ១ រាល់សំណើសុំរបស់កុមារ ឬរបស់ឪពុកម្តាយ ដើម្បីចូលឬចេញពីប្រទេស ក្នុងគោលបំណងទៅជួបជុំគ្រួសារឡើងវិញនោះ រដ្ឋជាភាគីត្រូវតែទទួលដោះស្រាយដោយអនុគ្រោះប្រកបដោយមនុស្សធម៌ និងឱ្យបានឆាប់រហ័សផង ។ម្យ៉ាងទៀតរដ្ឋជាភាគីត្រូវធានាថា ការស្នើសុំទាំងនោះនឹងមិននាំមកនូវផលវិបាកអាក្រក់អ្វីដល់អ្នកស្នើសុំ និងដល់សមាជិកទាំងឡាយនៃគ្រួសារនេះឡើយ ។

២. កុមារដែលមានឪពុកម្តាយរស់នៅក្នុងរដ្ឋផ្សេងៗពីគ្នា មានសិទ្ធិរក្សាចំណងមេត្រីភាពផ្ទាល់ខ្លួន និងទាក់ទងផ្ទាល់ជាមួយឪពុកម្តាយ លើកលែងតែក្នុងកាលៈទេសៈជាពិសេសចេញ ។ក្នុងទិសដៅនេះ និងដោយអនុលោមទៅតាមកាតព្វកិច្ចរបស់រដ្ឋជាភាគីដូចមានចែងនៅក្នុងមាត្រា៩ កថាខ័ណ្ឌ១នោះ រដ្ឋជាភាគីត្រូវគោរពសិទ្ធិរបស់កុមារឬឪពុកម្តាយរបស់កុមារ ក្នុងការចាកចេញពីប្រទេស រួមបញ្ចូលទាំងប្រទេសរបស់ខ្លួនផង ក៏ដូចជាសិទ្ធិចូលមកក្នុងប្រទេសរបស់ខ្លួនវិញដែរ ។ សិទ្ធិចាកចេញពីប្រទេសអាចត្រូវខាឃាំងបានតែតាមលក្ខណៈច្បាប់ ហើយដែលចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិនិងសេរីភាពរបស់អ្នកដទៃទៀត ដែលត្រូវបានទទួលស្គាល់ដោយអនុសញ្ញានេះ ។

## មាត្រា ១១

១. រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការនានា ដើម្បីទប់ស្កាត់មិនឱ្យមានការផ្ទេរចេញដោយខុសច្បាប់ និងការមិនអាចត្រឡប់មកវិញរបស់កុមារដែលនៅឯបរទេស ។

២. ក្នុងទិសដៅនេះ រដ្ឋជាភាគីត្រូវជម្រុញការចុះកិច្ចព្រមព្រៀងជាទ្វេភាគីឬជាពហុភាគី ឬចូលរួមទទួលស្គាល់កិច្ចព្រមព្រៀងនានាដែលមានស្រាប់ ។

## មាត្រា ១២

១. រដ្ឋជាភាគីត្រូវធានាដល់កុមារណាដែលមានសមត្ថភាពបញ្ចេញទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិក្នុងការបញ្ចេញទស្សនៈទាំងនោះដោយសេរី លើរាល់វិស័យទាំងអស់ដែលទាក់ទិននឹងកុមារ ។ ទស្សនៈរបស់កុមារត្រូវតែទទួលយកទៅពិចារណា ដោយថ្លឹងថ្លែងទៅតាមអាយុ និងភាពចាស់ទុំរបស់កុមារនោះ ។

២. ក្នុងទិសដៅនេះ កុមារត្រូវទទួលបានជាពិសេសនូវឱកាសបញ្ចេញមតិយោបល់របស់ខ្លួនក្នុងដំណើរការផ្នែកច្បាប់ និងផ្នែករដ្ឋបាលទាំងឡាយដែលទាក់ទិនដល់កុមារ ។ ការបញ្ចេញមតិយោបល់នេះអាចប្រព្រឹត្តទៅដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ឬតាមស្ថាប័នសមស្របណាមួយក្នុងលក្ខណៈមួយដែលស្របទៅតាមនីតិវិធីនៃច្បាប់ក្នុងប្រទេស ។

## មាត្រា ១៣

១. កុមារមានសិទ្ធិក្នុងការសម្តែងមតិដោយសេរី ។ សិទ្ធិនេះរួមមានសេរីភាពក្នុងការស្វែងរកសេរីភាពក្នុងការទទួល និងសេរីភាពក្នុងការផ្សព្វផ្សាយព័ត៌មាន និងផ្សព្វផ្សាយគំនិតគ្រប់ប្រភេទដោយគ្មានព្រំដែនអ្វីសោះឡើយ ទោះជាតាមការនិយាយស្តី តាមការសរសេរ ឬតាមការបោះពុម្ពនៅក្នុងទម្រង់ជាសិល្បៈ ឬតាមរយៈបណ្តាញឃោសនាប្រភេទណាក៏ដោយ ឱ្យតែជាជម្រើសរបស់កុមារ ។

២. ការប្រើប្រាស់សិទ្ធិនេះអាចស្ថិតនៅក្នុងកំហិតមួយចំនួន ប៉ុន្តែការដាក់កំហិតនេះអាចប្រព្រឹត្តទៅបាន តែល្គឹកណាដែលមានកំណត់ត្រឹមត្រូវតាមច្បាប់ និងភាពចាំបាច់:

ក. ដើម្បីគោរពសិទ្ធិ និងកិត្តិនាមរបស់អ្នកដទៃ ឬ

ខ. ដើម្បីការពារសន្តិសុខជាតិ ឬរបៀបរៀបរយសាធារណៈ ឬសុខភាពសាធារណៈ ឬសីលធម៌ ។

## មាត្រា ១៤

១. រដ្ឋជាភាគីត្រូវគោរពសិទ្ធិរបស់កុមារក្នុងការមានសេរីភាព ផ្នែកគំនិត ផ្នែកមនសិការ និងសាសនា ។

២. រដ្ឋជាភាគីត្រូវគោរពសិទ្ធិនិងកាតព្វកិច្ចរបស់ឪពុកម្តាយ និងរបស់អ្នកអាណាព្យាបាលស្របច្បាប់ ក្នុងការណែនាំកុមារ ក្នុងការប្រើប្រាស់សិទ្ធិទាំងនេះ តាមរបៀបមួយដែលស្របទៅតាមការវិវត្តខាងសមត្ថភាពរបស់កុមារ ។

៣. សេរីភាពក្នុងការសម្តែងអំពីសាសនា ឬសម្តែងអំពីជំនឿរបស់ខ្លួនអាចមានកម្រិតព្រំដែនតែល្គិកណាមានការកំណត់ត្រឹមត្រូវតាមច្បាប់និងភាពចាំបាច់ ដើម្បីការពារសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់ សុខភាព ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់អ្នកដទៃតែប៉ុណ្ណោះ ។

### មាត្រា ១៥

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការមានសេរីភាពចូលរួមជាមួយសមាគម និងសេរីភាពធ្វើការជួបជុំដោយសន្តិវិធី ។

២. គ្មានកំហិតណាមួយត្រូវបានដាក់ទៅលើសិទ្ធិទាំងនេះទេ លើកលែងតែកំហិតទាំងនោះត្រូវបានកំណត់ដោយស្របទៅតាមច្បាប់និងភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យដើម្បីជាផលប្រយោជន៍ដល់សន្តិសុខសង្គម ឬសុវត្ថិភាពសាធារណៈ របៀបរៀបរយសាធារណៈ ការការពារ សុខភាពសាធារណៈ ឬសីលធម៌ ឬក៏ដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

### មាត្រា ១៦

១. គ្មានកុមារណាម្នាក់ត្រូវបានជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់នៅក្នុងជីវិតឯកជន នៅក្នុងគ្រួសារ ក្នុងផ្ទះសម្បែង ឬការឆ្លងឆ្លើយគ្នា ព្រមទាំងការបំពារបំពានដោយខុសច្បាប់លើកិត្តិយស និងកិត្តិនាមរបស់ខ្លួនបានឡើយ ។

២. កុមារមានសិទ្ធិទទួលកិច្ចការពារផ្នែកផ្លូវច្បាប់តទល់នឹងការជ្រៀតជ្រែក និងបំពារបំពានអស់ទាំងនេះ ។

## មាត្រា ១៧

រដ្ឋជាភាគីទទួលស្គាល់តួនាទីជាសំខាន់របស់បណ្តាញឃោសនា ហើយធានាថា កុមារអាចទទួលបាននូវព័ត៌មាននិងឯកសារពីប្រភពប្លែកៗគ្នា ទាំងក្នុងប្រទេស និងអន្តរជាតិ ជាពិសេសគឺព័ត៌មាននិងឯកសារអប់រំពីផាសុកភាពផ្នែកសង្គម ស្មារតី និងសីលធម៌ និងសុខភាពផ្នែករាងកាយ និងសតិបញ្ញា។ ក្នុងទិសដៅនេះ រដ្ឋជាភាគីត្រូវ:

ក. លើកទឹកចិត្តប្រព័ន្ធឃោសនាឱ្យផ្សព្វផ្សាយព័ត៌មាន និងឯកសារដែលមានអត្ថប្រយោជន៍ផ្នែកសង្គម និងវប្បធម៌ដល់កុមារដោយស្របទៅតាមស្មារតីនៃមាត្រា ២៩។

ខ. លើកទឹកចិត្តកិច្ចសហប្រតិបត្តិការជាអន្តរជាតិក្នុងការផលិត ការផ្លាស់ប្តូរ និងការផ្សាយនូវព័ត៌មាននិងឯកសារដែលមានប្រភពប្លែកៗគ្នា ខាងវប្បធម៌ ប្រភពក្នុងស្រុកនិងអន្តរជាតិ។

គ. លើកទឹកចិត្តដល់ការផលិត និងការផ្សព្វផ្សាយសៀវភៅសម្រាប់កុមារ។

ឃ.លើកទឹកចិត្តបណ្តាញឃោសនាឱ្យមានការគិតគូរជាពិសេសដល់តម្រូវការផ្នែកភាសារបស់កុមារដែលជាក្រុមជនជាតិភាគតិច ឬជាម្ចាស់ស្រុក។

ង. លើកទឹកចិត្តដល់ការផលិតជាគោលការណ៍ណែនាំសមស្រប ដើម្បីការពារកុមារតទល់នឹងព័ត៌មាន ព្រមទាំងឯកសារទាំងឡាយដែលប៉ះពាល់ដល់ផាសុកភាពរបស់កុមារ ដោយយោងទៅលើបទបញ្ញត្តិនៃមាត្រា១៣ និង១៨។

## មាត្រា ១៨

១. រដ្ឋជាភាគីត្រូវប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីធានាឱ្យមានការទទួលស្គាល់គោលការណ៍ដែលថែងថា ទាំងឪពុកទាំងម្តាយ សុទ្ធតែមានការទទួលខុសត្រូវរួមក្នុងការចិញ្ចឹមបីបាច់ និងការអភិវឌ្ឍរបស់កុមារ។ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់ (បើសិនជាមាន) មានការទទួលខុសត្រូវជាចម្បងក្នុងការចិញ្ចឹមបីបាច់ និងការរីកចម្រើនលូតលាស់របស់កុមារ។ ផលប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារ គឺជាការគិតគូរជាមូលដ្ឋានរបស់ពួកគាត់។

២. ដើម្បីធានានិងជម្រុញការអនុវត្តសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ រដ្ឋជាភាគីត្រូវផ្តល់នូវជំនួយឧបត្ថម្ភសមស្របដល់ឪពុកម្តាយ និងអ្នកអាណាព្យាបាល

ស្របច្បាប់ ក្នុងការបំពេញភារកិច្ចចិញ្ចឹមបីបាច់កុមារ និងធានាការអភិវឌ្ឍនូវស្ថាប័ន ភាពងាយស្រួល និងសេវាកម្មនានាដែលទទួលបន្ទុកថែទាំកុមារ។

៣. រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការសមស្របនានា ដើម្បីធានាថាកុមារដែលមានឪពុកម្តាយជាអ្នកធ្វើការ បានទទួលនូវផលប្រយោជន៍ពីសេវាកម្មថែទាំកុមារ និងភាពងាយស្រួលទាំងឡាយ ទៅតាមលក្ខខណ្ឌដែលខ្លួនត្រូវទទួលបាន។

## មាត្រា ១៩

១. រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការច្បាប់ រដ្ឋបាល សង្គម និងផ្នែកអប់រំនានាដ៏សមស្រប ដើម្បីការពារកុមារតទល់នឹងរាល់ទម្រង់នៃអំពើហិង្សា ការបង្ករបួសស្នាម ឬការបំពារបំពាន ដែលប៉ះពាល់ដល់រាងកាយ ឬគំនិតបញ្ញា ការមិនអើពើ ឬការមិនគិតគូរដល់ ការធ្វើបាប ឬការកេងប្រវ័ញ្ច រួមទាំងការរំលោភបំពានផ្លូវភេទ ក្នុងពេលដែលកុមារស្ថិតនៅក្រោមការចិញ្ចឹមបីបាច់របស់ឪពុកឬម្តាយ អ្នកអាណាព្យាបាលស្របច្បាប់ ឬបុគ្គលផ្សេងៗទៀតដែលទទួលថែទាំកុមារ។

២. ជាការសមស្រប វិធានការការពារទាំងនេះគួររួមបញ្ចូលទាំងរាល់នីតិវិធីដ៏មានប្រសិទ្ធភាពទាំងឡាយ ក្នុងការបង្កើតនូវកម្មវិធីសង្គមនានា ដើម្បីផ្តល់កិច្ចគាំទ្រជាចាំបាច់ចំពោះកុមារ និងចំពោះអ្នកទាំងឡាយណាដែលទទួលថែទាំកុមារ ក៏ដូចជារាល់ទម្រង់ផ្សេងទៀត សម្រាប់ការបង្ការ និង សម្រាប់ការកំណត់អត្តសញ្ញាណ ការធ្វើរបាយការណ៍ ការសំអាង ការអង្កេត ការវិភាគពិនិត្យនិងការតាមដានលើរាល់ករណីនៃការធ្វើបាបកុមារ ដែលបានលើកឡើងខាងលើនេះ ហើយក្នុងករណីសមស្រប គឺសម្រាប់នីតិវិធីអន្តរាគមន៍ខាងផ្លូវច្បាប់ថែមទៀតផង។

## មាត្រា ២០

១. កុមារដែលត្រូវបានដកហូតជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍ពីមជ្ឈដ្ឋានគ្រួសារខ្លួន (ឬផ្អែកលើផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ មិនអនុញ្ញាតឱ្យកុមារនោះបន្តរស់នៅក្នុងមជ្ឈដ្ឋានបែបនេះបាន) មានសិទ្ធិទទួលបាននូវកិច្ចការពារ និងជំនួយឧបត្ថម្ភជាពិសេសពីរដ្ឋ។

២. ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន រដ្ឋជាភាគីត្រូវធានាដល់កុមារបែបនេះនូវវិធីថែទាំជំនួស ។

៣. កិច្ចថែទាំជំនួសនេះ អាចមានទម្រង់ជាការបញ្ចូលទៅរស់នៅតាមគ្រួសារ ជាបែប**កាហ្វាឡា** នៃច្បាប់អ៊ិស្លាម ជាការទទួលចិញ្ចឹមធ្វើជាកូន ឬបើសិនជាចាំបាច់ដាក់ឱ្យទៅនៅតាមស្ថាប័នថែទាំកុមារដែលមានលក្ខណៈសមស្រប ។ នៅពេលគិតពីដំណោះស្រាយបែបនេះ គេត្រូវយកចិត្តទុកដាក់លើភាពពេញចិត្តនៃការបន្តការចិញ្ចឹមថែទាំកុមារ ហើយនិងប្រភពជាតិសាសន៍ សាសនា វប្បធម៌ និងភាសារបស់កុមារនោះ ។

## មាត្រា ២១

រដ្ឋជាភាគីដែលទទួលស្គាល់ និងឬអនុញ្ញាតឱ្យមានប្រព័ន្ធសុំកូនចិញ្ចឹមត្រូវធានាថា ផលប្រយោជន៍ល្អបំផុតរបស់កុមារ គឺជាមូលដ្ឋានចម្បងដែលត្រូវតែពិចារណា ហើយរដ្ឋជាភាគីត្រូវ ៖

ក. ធានាថា មានតែអាជ្ញាធរមានសមត្ថកិច្ចទេ ដែលមានសិទ្ធិអនុញ្ញាតឱ្យមានការសុំកូនចិញ្ចឹម ដោយអនុលោមទៅតាមច្បាប់ និងនីតិវិធី ដែលអាចអនុវត្តបានក្នុងវិស័យនេះ និងឈរលើមូលដ្ឋាននៃព័ត៌មានត្រឹមត្រូវនិងទុកចិត្តបាន ហើយធានាថាការសុំកូនចិញ្ចឹមនេះ អាចធ្វើទៅបាន អាស្រ័យដោយស្ថានភាពរបស់កុមារទាក់ទិនទៅនឹងឪពុកម្តាយ សាច់ញាតិ និងអ្នកអាណាព្យាបាលស្របច្បាប់ ហើយបើសិនជាចាំបាច់ បុគ្គលទាំងឡាយដែលមានទាក់ទិនបានផ្តល់ការយល់ព្រមរបស់ខ្លួន លើការសុំកូនចិញ្ចឹមនេះ ដោយផ្អែកទៅលើការយល់ដឹងច្បាស់លាស់ និងការបំភ្លឺជាចាំបាច់រួចមក ។

ខ. ទទួលស្គាល់ថា ការសុំកូនចិញ្ចឹមជាអន្តរប្រទេសអាចចាត់ទុកជាមធ្យោបាយជំនួសមួយនៃការថែទាំកុមារ បើសិនជានៅក្នុងប្រទេសដើមកំណើតរបស់ខ្លួន កុមារមិនអាចបញ្ចូលទៅរស់នៅតាមគ្រួសារ ឬគ្មានការសុំចិញ្ចឹមធ្វើជាកូនតាមគ្រួសារ ឬមិនអាចទទួលបាននូវការថែទាំឱ្យបានសមស្របទេនោះ ។

គ. ធានាថា កុមារដែលត្រូវគេសុំយកទៅចិញ្ចឹមនៅឯប្រទេសផ្សេងទទួលបាននូវកិច្ចការពារ និងបទដ្ឋាននានា ដូចគ្នាទៅនឹងកិច្ចការពារហើយនិងបទដ្ឋាននានាដែលមាននៅក្នុងប្រទេសនោះ ។

ឃ. ប្រកាន់យកនូវរាល់វិធានការសមស្របនានាដើម្បីធានាថា ការសុំកូនចិញ្ចឹមជាអន្តរប្រទេសនេះ ពុំត្រូវបានប្រើប្រាស់ ដើម្បីរកចំណូលផ្នែកហិរញ្ញវត្ថុ ដោយរាល់បុគ្គលដែលមានការទាក់ទិនក្នុងរឿងនេះឡើយ ។

ង. ក្នុងករណីដែលសមស្រប ជម្រុញមុខសញ្ញានៃមាត្រានេះ ដោយការចុះកិច្ចព្រមព្រៀង ឬកិច្ចសម្របសម្រួលជាទ្វេភាគី ឬជាពហុភាគីហើយនៅក្នុងក្របខ័ណ្ឌនេះ ត្រូវធានាឱ្យបានថា ការយកកុមារទៅចិញ្ចឹមនៅឯប្រទេសផ្សេង ត្រូវបានចាត់ចែងឡើងដោយអាជ្ញាធរ ឬអង្គការមានសមត្ថកិច្ច។

## មាត្រា ២២

១. រដ្ឋជាភាគីត្រូវប្រកាន់យកនូវរាល់វិធានការសមស្របទាំងឡាយដើម្បីធានាឱ្យកុមារដែលស្វះស្វែងរកឋានៈជាអ្នកភៀសខ្លួន ឬដែលត្រូវចាត់ទុកជាអ្នកភៀសខ្លួន ដោយអនុលោមទៅតាមបញ្ញត្តិនៃនីតិវិធីរបស់ច្បាប់អន្តរជាតិនិងច្បាប់ជាតិ ដែលអាចអនុវត្តបាននៅក្នុងវិស័យនេះ ទោះជាកុមារនោះតែម្នាក់ឯង ឬដោយមានឪពុកម្ដាយ ឬអ្នកដទៃទៀតមកជាមួយក្ដី បានទទួលនូវកិច្ចការពារនិងជំនួយឧបត្ថម្ភមនុស្សធម៌ដ៏សមស្រប ក្នុងការប្រើប្រាស់សិទ្ធិដែលអាចអនុវត្តបានក្នុងអនុសញ្ញានេះ និងនៅក្នុងឯកសារអន្តរជាតិនានាស្ដីពីសិទ្ធិមនុស្ស ឬមនុស្សធម៌ដែលសាមីរដ្ឋបានចូលជាភាគី។

២. ក្នុងទិសដៅនេះនិងបើសិនជាយល់ថាចាំបាច់ រដ្ឋជាភាគីត្រូវផ្ដល់កិច្ចសហប្រតិបត្តិការដល់កិច្ចប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ និងរាល់អង្គការអន្តររដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាលមានសមត្ថកិច្ចទាំងឡាយដែលធ្វើសហការជាមួយអង្គការសហប្រជាជាតិ ដើម្បីការពារនិងជួយឧបត្ថម្ភកុមារទាំងនោះហើយនិងស្វែងរកឪពុកម្ដាយ ឬក៏សមាជិកផ្សេងទៀតនៃគ្រួសាររបស់កុមារភៀសខ្លួនទាំងអស់ ដើម្បីទទួលបាននូវព័ត៌មានចាំបាច់សម្រាប់ដល់ការជួបជុំគ្រួសារខ្លួនឡើងវិញ។ ដូចមានចែងក្នុងអនុសញ្ញានេះស្រាប់ ក្នុងករណីដែលរកមិនឃើញឪពុកម្ដាយ ឬសមាជិកផ្សេងទៀតនៃគ្រួសារនោះទេ កុមារត្រូវទទួលបានកិច្ចការពារដូចគ្នានឹងកុមារដែលបានបែកចេញជាអចិន្ត្រៃយ៍ ឬជាបណ្ដោះអាសន្នពីមជ្ឈដ្ឋានគ្រួសារខ្លួនដែរ ទោះជាបណ្ដាលមកពីមូលហេតុអ្វីក៏ដោយ។

## មាត្រា ២៣

១. រដ្ឋជាភាគីត្រូវទទួលស្គាល់ថា កុមារដែលមានពិការភាពផ្នែកស្មារតីបញ្ញា ឬរាងកាយ ត្រូវទទួលបាននូវជីវភាពរស់នៅមួយសមរម្យនិងពេញលេញ ក្នុងលក្ខខណ្ឌមួយដែលធានា

នូវភាពថ្លៃថ្នូរ ភាពជាម្ចាស់ការ និងជួយសម្រួលឱ្យកុមារអាចចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍។

២. រដ្ឋជាភាគីត្រូវទទួលស្គាល់សិទ្ធិរបស់កុមារពិការ ក្នុងការទទួលបាននូវការថែទាំពិសេស ហើយអាស្រ័យទៅតាមធនធានដែលមាន ជួយជម្រុញនិងពង្រីកនូវជំនួយឧបត្ថម្ភឱ្យដល់កុមារដែលមានលក្ខណៈបែបនេះ និងដល់អ្នកដែលទទួលខុសត្រូវក្នុងការថែទាំកុមារនេះទៀតផង បើសិនជាមានសំណើសុំដែលសមស្របទៅនឹងស្ថានភាពរបស់កុមារ និងរបស់ឪពុកម្ដាយ ឬអ្នកទទួលថែទាំកុមារនោះ។

៣. ដោយទទួលស្គាល់ពីតម្រូវការជាពិសេសរបស់កុមារពិការ ជំនួយឧបត្ថម្ភដែលត្រូវផ្ដល់ដោយអនុលោមទៅតាមកថាខ័ណ្ឌ២នៃមាត្រានេះ ត្រូវតែផ្ដល់ឱ្យដោយឥតគិតថ្លៃ (បើសិនជាមានលទ្ធភាព) ដោយយោងទៅលើធនធានហិរញ្ញវត្ថុរបស់ឪពុកម្ដាយ ឬរបស់អ្នកផ្សេងទៀតដែលទទួលថែទាំកុមារ ហើយត្រូវគិតគូរយ៉ាងណាដើម្បីឱ្យកុមារពិការអាចឈោងចាប់និងទទួលបានដោយផ្ទាល់នូវការអប់រំ ការបណ្ដុះបណ្ដាល ការថែទាំសុខភាព សេវាស្តារនីតិសម្បទាឡើងវិញ ការរៀបចំខ្លួន ដើម្បីបំពេញការងារ និងលំហែកាយក្នុងលក្ខណៈមួយដែលអាចឱ្យកុមារបន្ស៊ីខ្លួនបានយ៉ាងពេញលេញបំផុតទៅក្នុងសង្គម និងរីកចម្រើនលូតលាស់ជាបុគ្គល រួមបញ្ចូលទាំងការរីកចម្រើនផ្នែកវប្បធម៌ និងស្មារតីផង។

៤. ក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ រដ្ឋជាភាគីត្រូវជម្រុញនូវការផ្លាស់ប្ដូរព័ត៌មានសមស្របទាក់ទិនទៅនឹងវិស័យថែទាំសុខភាពដែលអាចការពារបាន ហើយនិងការព្យាបាលផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងដំណើរសរីរាង្គដល់កុមារពិការ រួមបញ្ចូលទាំងការផ្សាយ និងការអនុញ្ញាតឱ្យទទួលបាននូវព័ត៌មានទាក់ទិនទៅនឹងវិធីស្តារនីតិសម្បទាឡើងវិញ ការអប់រំនិងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្នុងទិសដៅជួយឱ្យរដ្ឋជាភាគីបង្កើនសមត្ថភាពនិងជំនាញរបស់ខ្លួន ហើយនិងធ្វើឱ្យមានបទពិសោធទូលំទូលាយនៅក្នុងវិស័យនេះ។ ក្នុងចំណុចនេះត្រូវយកចិត្តទុកដាក់ ជាពិសេសលើតម្រូវការនៃប្រទេសកំពុងអភិវឌ្ឍ។

## មាត្រា ២៤

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការទទួលបាននូវកម្រិតសុខភាពដ៏ខ្ពស់បំផុតដែលអាចធ្វើទៅបាន ហើយនិងទទួលបាននូវរាល់ភាពងាយស្រួលក្នុងការព្យាបាលជម្ងឺ និងការស្តារសុខភាពឡើងវិញ។ រដ្ឋជាភាគីត្រូវប្រឹងប្រែងដើម្បីធានាឱ្យបានថា គ្មានកុមារណាម្នាក់ត្រូវបាត់បង់សិទ្ធិទទួលបាននូវការថែទាំសុខភាពទាំងនេះឡើយ ។

២. រដ្ឋជាភាគីត្រូវប្រឹងប្រែងអនុវត្តឱ្យបានសម្រេចទាំងស្រុងនូវសិទ្ធិនេះ ហើយជាពិសេសត្រូវប្រកាន់យកនូវវិធានការសមស្របទាំងឡាយដើម្បី ៖

(ក) កាត់បន្ថយមរណភាពទារក និងកុមារ

(ខ) ធានាផ្តល់ដល់គ្រប់កុមារទាំងអស់នូវជំនួយវេជ្ជសាស្ត្រ និងការថែទាំសុខភាព ដោយផ្តោតជាពិសេសលើការថែទាំសុខភាពបឋម

(គ) លុបបំបាត់ជម្ងឺ និងកង្វះអាហារូបត្ថម្ភ ដោយរួមទាំងនៅក្នុងក្របខ័ណ្ឌនៃការថែទាំសុខភាពបឋមផង ជាពិសេសតាមរយៈការអនុវត្តបច្ចេកវិជ្ជាដែលមានស្រាប់និងដែលងាយរក និងតាមរយៈការផ្គត់ផ្គង់ស្បៀងអាហារដែលមានជីវជាតិគ្រប់គ្រាន់ និងទឹកស្អាត ដោយវិភាគទៅលើគ្រោះថ្នាក់ និងភាពប្រថុយប្រថានដែលបណ្តាលមកពីភាពកខ្វក់នៃបរិស្ថាន ។

(ឃ) ធានានូវការថែទាំសុខភាពដល់មាតានៅមុននិងក្រោយពេលសម្រាលកូន ។

(ង) ធានាធ្វើយ៉ាងណាឱ្យមនុស្សគ្រប់ក្រុមនៅក្នុងសង្គម ជាពិសេសឪពុកម្តាយនិងកុមារទទួលបាននូវព័ត៌មាននិងការអប់រំស្តីពីសុខភាព និងអាហារូបត្ថម្ភ អត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្តាយ អនាម័យ និងការសម្អាតបរិស្ថាន ហើយនិងការបង្ការពីគ្រោះថ្នាក់នានា ព្រមទាំងផ្តល់នូវការគាំទ្រដើម្បីឱ្យអ្នកទាំងនោះអាចប្រើប្រាស់ប្រកបដោយផលប្រយោជន៍នូវចំណេះដឹងជាមូលដ្ឋានទាំងនេះ ។

(ច) អភិវឌ្ឍការថែទាំសុខភាពដែលអាចការពារបាន ណែនាំដល់ឪពុកម្តាយ និងផ្តល់ការអប់រំ និងសេវានានា អំពីផែនការគ្រួសារ ។

៣. រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការដ៏មានប្រសិទ្ធភាពនិងដ៏សមស្របក្នុងការលុបបំបាត់រាល់ទម្លាប់តាមបែបបុរាណដែលប៉ះពាល់ដល់សុខភាពកុមារ ។

៤. រដ្ឋជាភាគីសន្យាថានឹងជម្រុញ និងលើកទឹកចិត្តកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងទិសដៅឈានជាជំហាន១ធ្វើឱ្យបានសម្រេចទាំងស្រុងនូវសិទ្ធិដែលបានទទួលស្គាល់នៅក្នុងមាត្រានេះ។ ក្នុងប្រការនេះ ត្រូវយកចិត្តទុកដាក់ជាពិសេសដល់តម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍ។

## មាត្រា ២៥

រដ្ឋជាភាគីត្រូវទទួលស្គាល់ចំពោះកុមារដែលត្រូវអាជ្ញាធរមានសមត្ថកិច្ចបានទុកដាក់ដើម្បីធ្វើការថែទាំ ដើម្បីការពារ ឬដើម្បីព្យាបាលខាងផ្នែករាងកាយឬសតិបញ្ញា នូវសិទ្ធិទទួលបាននូវការត្រួតពិនិត្យជាទៀងទាត់លើការព្យាបាល ការថែទាំ ដែលផ្តល់ទៅឱ្យកុមារនោះ ក៏ដូចជាការត្រួតពិនិត្យទៅលើកាលៈទេសៈផ្សេងទៀតនៃការទុកដាក់កុមារនោះផងដែរ។

## មាត្រា ២៦

១. រដ្ឋជាភាគីត្រូវទទួលស្គាល់នូវសិទ្ធិរបស់កុមារគ្រប់រូប ក្នុងការទទួលបាននូវផលប្រយោជន៍ពីសន្តិសុខសង្គម ដោយរួមទាំងកិច្ចធានារ៉ាប់រងសង្គមផង ហើយត្រូវប្រកាន់យកវាល់វិធានការចាំបាច់ទាំងឡាយ ដើម្បីធានាឱ្យបានសម្រេចទាំងស្រុងនូវសិទ្ធិនេះ ដោយស្របទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន។

២. ផលប្រយោជន៍ទាំងឡាយ ប្រសិនបើសមស្រប ត្រូវតែផ្តល់ឱ្យដោយយោងទៅលើធនធាន និងស្ថានភាពរបស់កុមារ និងអ្នកដែលទទួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់កុមារ ក៏ដូចជាយោងទៅលើការពិចារណាផ្សេង១ទៀត ដែលទាក់ទិនទៅនឹងសំណើសុំផលប្រយោជន៍ទាំងឡាយ ដែលបានស្នើឡើងដោយកុមារឬក្នុងនាមកុមារនោះ។

## មាត្រា ២៧

១. រដ្ឋជាភាគីទទួលស្គាល់ថា កុមារគ្រប់រូបសុទ្ធតែមានសិទ្ធិក្នុងការមានកម្រិតជីវភាពរស់នៅសមរម្យមួយ ដែលធានាបានដល់ការអភិវឌ្ឍផ្នែករាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់កុមារ។

២. ឪពុកម្តាយ ឬអ្នកដទៃទៀតដែលទទួលខុសត្រូវលើកុមារ មានភារកិច្ចទទួលខុសត្រូវជាចម្បងក្នុងការធានានូវកម្រិតជីវភាពរស់នៅមួយចាំបាច់ដល់ការអភិវឌ្ឍរបស់កុមារក្នុងកម្រិតនៃលទ្ធភាពនិងសមត្ថភាពហិរញ្ញវត្ថុរបស់ខ្លួន។

៣. ដោយយោលទៅតាមស្ថានភាពជាតិនិងក្នុងកម្រិតមធ្យោបាយរបស់ខ្លួន រដ្ឋជាភាគីត្រូវប្រកាន់យកនូវវិធានការសមស្រប ដើម្បីជួយឧបត្ថម្ភដល់ឪពុកម្តាយ ឬដល់អ្នកដែលមានការទទួលខុសត្រូវលើកុមារ ក្នុងការអនុវត្តសិទ្ធិនេះ ហើយនៅក្នុងករណីដែលមានតម្រូវការត្រូវផ្តល់ជំនួយឧបត្ថម្ភផ្នែកសម្ភារ និងកម្មវិធីគាំពារទាំងឡាយ ជាពិសេសនៅក្នុងបញ្ហាហូបចុក សំលៀកបំពាក់ និងផ្ទះសម្បែង។

៤. រដ្ឋជាភាគីត្រូវប្រកាន់យកនូវវិធានការសមស្របទាំងអស់ ដើម្បីធានាឱ្យកុមារទទួលបាននូវប្រាក់អាហារកិច្ចពីឪពុកម្តាយ ឬពីអ្នកដទៃផ្សេងទៀតដែលទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុលើកុមារទាំងនៅក្នុងនិងក្រៅប្រទេស។ ជាពិសេសក្នុងករណី ដែលអ្នកមានការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុលើកុមាររស់នៅក្នុងរដ្ឋផ្សេងពីរដ្ឋដែលកុមាររស់នៅ នោះរដ្ឋជាភាគីត្រូវជម្រុញឱ្យមានការចូលរួមជាភាគីនៅក្នុងកិច្ចព្រមព្រៀងជាអន្តរជាតិ ឬក៏ចុះជាកិច្ចព្រមព្រៀងបែបនេះ ក៏ដូចជាការអនុម័តនូវរាល់កិច្ចសម្របសម្រួលនានាដែលសមស្រប។

## មាត្រា ២៨

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារ ក្នុងការទទួលបាននូវការសិក្សាអប់រំ ហើយក្នុងទិសដៅឈានជាជំហានៗទៅសម្រេចបាននូវសិទ្ធិនេះ និងដោយឈរលើមូលដ្ឋាននៃលទ្ធភាពស្មើគ្នា ជាពិសេសរដ្ឋជាភាគីត្រូវ :

(ក) ធ្វើឱ្យការសិក្សាកម្រិតបឋមសិក្សា មានលក្ខណៈជាកាតព្វកិច្ច ហើយឥតបង់ថ្លៃសម្រាប់គ្រប់ៗគ្នា។

(ខ) លើកទឹកចិត្តដល់ការពង្រីកទម្រង់នានានៃផ្នែកមធ្យមសិក្សា រួមទាំងផ្នែកចំណេះទូទៅ ទាំងផ្នែកវិជ្ជាជីវៈ បើកទូលាយ និងបើកទទួលផ្នែកនេះដល់កុមារគ្រប់ៗរូប ហើយនិងប្រកាន់យកនូវវិធានការសមស្របនានា ដូចជាការបញ្ចូលការរៀនសូត្រដោយឥត

បង់ថ្លៃ ព្រមទាំងការផ្តល់ជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុក្នុងករណីដែលមានតម្រូវការជាដើម ។

(គ) ធានាតាមគ្រប់មធ្យោបាយដែលមាន ឱ្យគ្រប់ៗគ្នាអាចចូលរៀនក្នុងឧត្តមសិក្សាបានអាស្រ័យដោយសមត្ថភាពរបស់ម្នាក់ៗ ។

(ឃ) បើកចំហ និងបើកទូលាយនូវព័ត៌មាន និងការណែនាំតម្រង់ទិសផ្នែកអប់រំ ព្រមទាំងផ្នែកវិជ្ជាជីវៈដល់គ្រប់កុមារទាំងអស់ ។

(ង) ប្រកាន់យកនូវវិធានការនានាដើម្បីលើកទឹកចិត្តឱ្យមានវត្តមានជាទៀងទាត់នៅក្នុងសាលា និងកាត់បន្ថយអត្រាបោះបង់ចោលការសិក្សា ។

២. រដ្ឋជាភាគីត្រូវប្រកាន់យកនូវវិធានការសមស្របនានា ដើម្បីធានាថា វិន័យរបស់សាលាត្រូវបានដាក់ឱ្យអនុវត្តក្នុងលក្ខណៈមួយ ដែលស្របគ្នាទៅនឹងភាពថ្លៃថ្នូរជាមនុស្សរបស់កុមារ ហើយនិងស្របតាមអនុសញ្ញានេះ ។

៣. រដ្ឋជាភាគីត្រូវជម្រុញ និងលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យនានាដែលទាក់ទិនដល់ការអប់រំ ជាពិសេសក្នុងទស្សនៈរួមចំណែកលុបបំបាត់ភាពល្ងង់ខ្លៅ និងអនក្ខរភាពនៅទូទាំងពិភពលោក និងសម្រួលដល់ការឈោងចាប់យកនូវរាល់ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស និងវិធីបង្រៀនសម័យទំនើប ។ ក្នុងចំណុចនេះត្រូវយកចិត្តទុកដាក់ជាពិសេសដល់តម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍ ។

## មាត្រា ២៩

១. រដ្ឋជាភាគីឯកភាពថា ការអប់រំកុមារត្រូវតែឆ្ពោះទៅរក ៖

(ក) ការអភិវឌ្ឍឱ្យដល់កំពូលនៃបុគ្គលភាព ផ្នែកនិស្ស័យ ព្រមទាំងសមត្ថភាពខាងសតិបញ្ញា និងរូបរាងកាយរបស់កុមារ ។

(ខ) ការអភិវឌ្ឍនៃការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានទាំងឡាយ ក៏ដូចជាការគោរពដល់គោលការណ៍ទាំងឡាយដែលមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ។

(គ) ការអភិវឌ្ឍនៃការគោរពឪពុកម្តាយរបស់ខ្លួន អត្តសញ្ញាណវប្បធម៌ ភាសា និងតម្លៃរបស់ខ្លួនផ្ទាល់ ការគោរពតម្លៃជាតិនៃប្រទេសដែលកុមារកំពុងរស់នៅ ប្រទេសដែលជាដើមកំណើតខ្លួន និងអារ្យធម៌នានាដែលខុសប្លែកពីអារ្យធម៌របស់ខ្លួនផ្ទាល់ ។

(ឃ) ការរៀបចំកុមារត្រៀមសម្រាប់ជីវិតប្រកបដោយការទទួលខុសត្រូវនៅក្នុងសង្គមមានសេរីភាព ក្នុងស្មារតីនៃការយោគយល់ សន្តិភាព ភាពអនុគ្រោះ ភាពស្មើគ្នារវាងភេទ ហើយនិងមិត្តភាពរវាងប្រជាជនទាំងអស់ដោយមិនប្រកាន់ពូជសាសន៍ ជាតិក្រុមសាសនា និងបុគ្គលទាំងឡាយដែលជាម្ចាស់ស្រុក ។

(ង) ការរីកចម្រើននៃការគោរពបរិស្ថានធម្មជាតិ ។

២. គ្មានផ្នែកណាមួយនៃមាត្រានេះ ឬមាត្រា២៨ ត្រូវបានយកមកបកស្រាយតាមរបៀបមួយដែលប៉ះពាល់ទៅលើសេរីភាពរបស់បុគ្គល ឬស្ថាប័ននានាក្នុងការបង្កើតនិងដឹកនាំគ្រឹះស្ថានសិក្សានោះឡើយ ក្នុងលក្ខខណ្ឌដែលគោលការណ៍ទាំងឡាយ ដែលបានចែងនៅក្នុងកថាខ័ណ្ឌ១នៃមាត្រានេះបានគោរព ហើយការអប់រំដែលត្រូវបង្ហាត់បង្ហាញនៅក្នុងគ្រឹះស្ថាននោះ ត្រឹមត្រូវទៅតាមបទដ្ឋានអប្បបរមាដែលកំណត់ឡើងដោយរដ្ឋ ។

## មាត្រា ៣០

នៅក្នុងរដ្ឋដែលមានក្រុមជនជាតិភាគតិចផ្នែកពូជសាសន៍ សាសនា ឬភាសា ឬក៏មានពួកបុគ្គលដែលជាអ្នកស្រុកអាយ កុមារដែលស្ថិតនៅក្នុងក្រុមភាគតិចបែបនេះ ឬក៏ដែលជាអ្នកស្រុកអាយនោះ មិនត្រូវបានដកហូតសិទ្ធិមានជីវភាពវប្បធម៌ ផ្សព្វផ្សាយ និងគោរពសាសនា ឬប្រើប្រាស់ភាសារបស់ខ្លួនផ្ទាល់ រួមជាមួយនឹងសមាជិកឯទៀតនៃសហគមន៍របស់ខ្លួនឡើយ ។

## មាត្រា ៣១

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការសម្រាកនិងលំហែ ក្នុងការលេងល្បែងកម្សាន្តនិងសកម្មភាពលំហែ សមស្របទៅតាមអាយុរបស់កុមារ និងសិទ្ធិចូលរួមដោយសេរីនៅក្នុងជីវភាពវប្បធម៌ និង សិល្បៈ ។

២. រដ្ឋជាភាគីត្រូវគោរពនិងជម្រុញសិទ្ធិរបស់កុមារ ក្នុងការរួមចំណែកយ៉ាងពេញលេញនៅក្នុងជីវភាពវប្បធម៌ និងសិល្បៈ និងត្រូវលើកទឹកចិត្តដល់ការផ្ដល់នូវលទ្ធភាពយ៉ាងសមស្រប និងដោយស្មើភាពនូវការលំហែ ហើយនិងសកម្មភាពកម្សាន្ត ផ្នែកវប្បធម៌និងសិល្បៈទាំងឡាយ ។

## មាត្រា ៣២

១. រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការទទួលបានកិច្ចការពារតទល់នឹងការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងការពារពីរាល់ការងារទាំងឡាយណាដែលអាចប៉ះពាល់ ឬរំខានដល់ការអប់រំរបស់កុមារ ឬដែលអាចបំផ្លាញសុខភាពកុមារ ឬការអភិវឌ្ឍខាងផ្នែករាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់កុមារ ។

២. រដ្ឋជាភាគីត្រូវប្រកាន់យករាល់វិធានការច្បាប់ រដ្ឋបាល សង្គម និងអប់រំ ដើម្បីធានាដល់ការអនុវត្តមាត្រានេះ ។ ក្នុងទិសដៅនេះ និងដោយយោងទៅលើបទបញ្ញត្តិនៃឯកសារអន្តរជាតិឯទៀតៗដែលទាក់ទិននោះ រដ្ឋជាភាគីជាពិសេសត្រូវ :

(ក) កំណត់អាយុអប្បបរមា ឬរាល់អាយុអប្បបរមា សម្រាប់ទទួលឱ្យចូលធ្វើការ ។

(ខ) កំណត់នូវបញ្ញត្តិសមស្របស្ដីអំពីម៉ោងពេល និងលក្ខខណ្ឌការងារ ។

(គ) កំណត់ឡើងនូវទោស និងទណ្ឌកម្មផ្សេងៗទៀតដ៏សមស្រប ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវមាត្រានេះ ។

## មាត្រា ៣៣

រដ្ឋជាភាគីត្រូវប្រកាន់យករាល់វិធានការសមស្រប រួមបញ្ចូលទាំងវិធានការច្បាប់ រដ្ឋបាល សង្គម និងអប់រំផង ដើម្បីការពារកុមារតទល់នឹងការប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀនស្រវឹង និងសារជាតិទាក់ទងទៅនឹងចិត្តសាស្ត្រ ដូចដែលត្រូវបានកំណត់ដោយសន្ធិសញ្ញាអន្តរជាតិនានាដែលទាក់ទិនទៅនឹងបញ្ហានេះ ក៏ដូចជាដើម្បីបង្ការការប្រើប្រាស់កុមារក្នុងការផលិត និងជួញដូរដោយខុសច្បាប់នូវប្រភេទសារជាតិទាំងនេះ ។

## មាត្រា ៣៤

រដ្ឋជាភាគីសន្យាថា នឹងការពារកុមារតទល់នឹងរាល់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ។ ក្នុងទិសដៅនេះ រដ្ឋជាភាគីត្រូវប្រកាន់យកជាពិសេសនូវវិធានការសមស្របក្នុងក្របខ័ណ្ឌជាតិ ទ្វេភាគី និងពហុភាគី ដើម្បីខាយាំង :

(ក) ការញុះញង់ ឬការបង្ខិតបង្ខំកុមារឱ្យប្រព្រឹត្តសកម្មភាពផ្លូវភេទដោយខុសច្បាប់។

(ខ) ការប្រើកុមារជាផ្លូវអាជីវកម្មក្នុងពេស្យាកម្ម ឬរាល់ការប្រព្រឹត្តផ្លូវភេទដោយខុសច្បាប់ផ្សេងទៀត។

(គ) ការប្រើកុមារជាផ្លូវអាជីវកម្មនៅក្នុងការសម្តែង ឬផលិតចេញជាសម្ភារផ្ទៃកកាមសាស្រ្តអាសគ្រាម។

## មាត្រា ៣៥

រដ្ឋជាភាគីត្រូវប្រកាន់យកនូវរាល់វិធានការសមស្រប ក្នុងក្របខ័ណ្ឌជាតិ ទ្វេភាគី ឬពហុភាគី ដើម្បីខាយាំងការចាប់ពង្រត់ ការលក់ ឬជួញដូរកុមារ ទោះជាក្នុងទិសដៅអ្វី ឬក្នុងទម្រង់ណាក៏ដោយ។

## មាត្រា ៣៦

រដ្ឋជាភាគីត្រូវការពារកុមារតទល់នឹងរាល់ទម្រង់ផ្សេងទៀតនៃការជិះជាន់ដែលប៉ះពាល់ដល់គ្រប់ទិដ្ឋភាពនៃផាសុកភាពរបស់កុមារ។

## មាត្រា ៣៧

រដ្ឋជាភាគីត្រូវធានាថា :

(ក) គ្មានកុមារណាម្នាក់ត្រូវរងទារុណកម្ម ឬទទួលការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណា ដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្សឡើយ។ ការកាត់ទោសប្រហារជីវិត ឬការដាក់គុកអស់មួយជីវិត ដោយគ្មានលទ្ធភាពដោះលែង មិនត្រូវអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តដោយបុគ្គលដែលមានអាយុតិចជាងដប់ប្រាំបីឆ្នាំឡើយ។

(ខ) គ្មានកុមារណាម្នាក់ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬដោយតាមអំពើចិត្តនោះឡើយ ។ ការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារត្រូវធ្វើដោយស្របតាមច្បាប់ហើយត្រូវប្រើតែសម្រាប់វិធានការចុងក្រោយ និងសម្រាប់តែក្នុងរយៈពេលយ៉ាងខ្លីដោយសមស្រប ។

(គ) រាល់កុមារដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបាននូវការប្រព្រឹត្តមកលើពួកគេប្រកបដោយមនុស្សធម៌ និងដោយការគោរពចំពោះភាពថ្លៃថ្នូរដែលមិនអាចកាត់ផ្តាច់បានរបស់មនុស្ស ហើយក្នុងលក្ខណៈមួយដែលយោងទៅតាមតម្រូវការរបស់បុគ្គលក្នុងអាយុនេះ ។ ជាពិសេស រាល់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពត្រូវតែបំបែកចេញពីមនុស្សពេញវ័យ លើកលែងតែផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារមិនតម្រូវឱ្យធ្វើយ៉ាងនេះ ទន្ទឹមនេះ កុមារនៅតែមានសិទ្ធិរក្សាទំនាក់ទំនងជាមួយគ្រួសារខ្លួន តាមរយៈការឆ្លើយឆ្លង និងការជួបសួរសុខទុក្ខ លើកលែងតែក្នុងកាលៈទេសៈជាពិសេសដោយឡែក ។

(ឃ) រាល់កុមារដែលត្រូវបានដកហូតយកសេរីភាព មានសិទ្ធិទទួលបានយ៉ាងឆាប់រហ័សនូវជំនួយផ្នែកផ្លូវច្បាប់ និងក្នុងផ្នែកផ្សេងៗទៀតដែលសមស្រប ក៏ដូចជាសិទ្ធិក្នុងការតវ៉ារកភាពស្របច្បាប់នៃការដកហូតសេរីភាពខ្លួននេះ នៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ដែលឯករាជ្យ និងមិនលំអៀង ហើយនិងមានសិទ្ធិទទួលបានសេចក្តីសម្រេចយ៉ាងឆាប់រហ័សចំពោះទង្វើនេះ ។

### មាត្រា ៣៨

១. រដ្ឋជាភាគីសន្យាគោរព និងធានាឱ្យមានការគោរពនូវបទបញ្ញត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិដែលត្រូវអនុវត្ត មកលើខ្លួននៅក្នុងជម្លោះដោយអាវុធ ហើយដែលទាក់ទិនដល់កុមារ ។

២. រដ្ឋជាភាគីត្រូវប្រកាន់យករាល់វិធានការដែលធ្វើទៅបាន ដើម្បីធានាថាបុគ្គលដែលមិនទាន់ដល់អាយុ១៥ឆ្នាំ មិនត្រូវឱ្យចូលរួមដោយផ្ទាល់នៅក្នុងចំបាំងឡើយ ។

៣. រដ្ឋជាភាគីត្រូវចៀសវាងការរើសបុគ្គលដែលមានអាយុមិនទាន់ដល់១៥ឆ្នាំ ឱ្យចូលក្នុងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនឡើយ ។ នៅពេលកេណ្ឌរើសក្នុងចំណោមបុគ្គលទាំងឡាយ ដែល

មានអាយុចាប់ពី១៥ឆ្នាំឡើងទៅ តែមិនទាន់ដល់អាយុ១៨ឆ្នាំ នោះរដ្ឋជាភាគីត្រូវប្រឹងប្រែងជ្រើសរើសជាអាទិភាពអ្នកដែលមានអាយុច្រើនជាងគេ ។

៤. ស្របទៅតាមកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវការពារប្រជាជនស៊ីវិលនៅក្នុងជម្លោះដោយអាវុធ ដោយអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិនោះ រដ្ឋជាភាគីត្រូវប្រកាន់យកនូវរាល់វិធានការដែលអាចធ្វើបាន ដើម្បីធានាដល់ការការពារ និងការថែទាំដល់កុមារដែលត្រូវប៉ះពាល់ដោយជម្លោះប្រដាប់អាវុធ ។

## មាត្រា ៣៩

រដ្ឋជាភាគីត្រូវប្រកាន់យករាល់វិធានការសមស្របទាំងអស់ ដើម្បីជម្រុញការស្តារផ្នែករាងកាយ និងផ្នែកចិត្តសាស្ត្រ ក៏ដូចជាការធ្វើសមាហរណកម្មនៃកុមារដែលជាជនរងគ្រោះដោយគ្មានការថែទាំ ការជិះជាន់ឬការបំពាន ទារុណកម្ម ឬទម្រង់ផ្សេងៗនៃការប្រព្រឹត្ត ឬការផ្តន្ទាទោសដែលឃោរឃៅ អមនុស្សធម៌ និងដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ឬដោយសារជម្លោះដោយអាវុធ ។ ការស្តារនីតិសម្បទាឡើងវិញ និងការបញ្ជូនទៅក្នុងសង្គមវិញនេះ ត្រូវប្រព្រឹត្តទៅក្នុងលក្ខណៈមួយដែលអំណោយផលដល់ផ្នែកសុខភាព ដល់ស្មារតី ស្វ័យគោរព ហើយនិងភាពថ្លៃថ្នូររបស់កុមារ ។

## មាត្រា ៤០

១. រដ្ឋជាភាគីទទួលស្គាល់កុមារដែលត្រូវសង្ស័យ ចោទប្រកាន់ ឬត្រូវបានទទួលស្គាល់ថាបានប្រព្រឹត្តបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌ នូវសិទ្ធិទទួលបានការប្រព្រឹត្តមកលើ ដែលឈរលើស្មារតីនៃការលើកកម្ពស់សេចក្តីថ្លៃថ្នូរ និងតម្លៃរបស់កុមារ ដែលការនេះជួយពង្រឹងកុមារឱ្យមានការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានរបស់អ្នកដទៃ និងក៏ឈរលើការគិតគូរដល់អាយុរបស់កុមារ ក៏ដូចជាភាពចាំបាច់ក្នុងការជួយសម្រួលការបញ្ចូលកុមារមកក្នុងសង្គមជាតិវិញ ហើយនិងជួយសម្រួលដល់កុមារឱ្យប្រកាន់យកនូវតួនាទីស្ថាបនាមួយនៅក្នុងសង្គម ។

២. ក្នុងទិសដៅនេះ និងដោយយោងទៅតាមរាល់បទបញ្ញត្តិនៃឯកសារអន្តរជាតិដែលទាក់ទិនទៅនឹងបញ្ហានេះ រដ្ឋជាភាគីត្រូវធានាជាពិសេសថា :

(ក) គ្មានកុមារណាម្នាក់ត្រូវបានសង្ស័យ ចោទប្រកាន់ ឬត្រូវបានទទួលស្គាល់ថាបានប្រព្រឹត្តបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌលើទង្វើ ឬការខកខានទាំងឡាយណាដែលមិនត្រូវបានហាមឃាត់ដោយច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងពេលដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើយ ។

(ខ) កុមារគ្រប់រូបដែលត្រូវបានសង្ស័យ ឬចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌ យ៉ាងហោចណាស់ត្រូវទទួលបាននូវកិច្ចធានាដូចខាងក្រោមនេះ :

ខ-១- ចាត់ទុកជាគ្មានកំហុសរហូតដល់ពេលដែលពិរុទ្ធភាពត្រូវបានរកឃើញស្របតាមច្បាប់ ។

ខ-២- ទទួលបានព័ត៌មានជាបន្ទាន់និងដោយផ្ទាល់ស្តីពីបទចោទប្រកាន់ដែលមានមកលើខ្លួន បើសិនជាសមស្រប ទទួលតាមរយៈឪពុកម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់ខ្លួន ហើយនិងទទួលបាននូវជំនួយផ្នែកច្បាប់សមស្រប ឬក្នុងទម្រង់ផ្សេងៗទៀតក្នុងការរៀបចំ និងការការពារខ្លួន ។

ខ-៣- ទទួលបានការដោះស្រាយសំណុំរឿងដោយគ្មានការពន្យាពេល ដោយអាជ្ញាធរ ឬស្ថាប័នតុលាការដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀងនៅក្នុងការជំនុំជំរះមួយដែលស្របតាមច្បាប់ និងដោយមានជំនួយផ្នែកច្បាប់ឬជំនួយផ្សេងៗទៀត លើកលែងតែមិនមានការចាត់ថាប្រការនេះ គឺផ្ទុយនឹងផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារទេនោះ ជាពិសេសដោយយោងទៅលើអាយុ ឬស្ថានភាពរបស់កុមារ ដោយមានវត្តមានរបស់ឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារផង ។

ខ-៤- មិនត្រូវទទួលការបង្ខិតបង្ខំឱ្យធ្វើជាសាក្សី ឬទទួលសារភាពកំហុសណាឡើយ ទទួលសាកសួរ ឬចាត់ចែងឱ្យសួរសាក្សីដើមចោទ និងអញ្ជើញឱ្យចូលរួម ព្រមទាំងទទួលសាកសួរសាក្សីចុងចោទ ក្នុងលក្ខខណ្ឌស្មើភាព ។

ខ-៥- បើសិនជាគេទទួលស្គាល់ថា បានល្មើសនឹងច្បាប់ព្រហ្មទណ្ឌ កុមារអាចតវ៉ាសើរើសេចក្តីសម្រេចនេះ ឬរាល់វិធានការឯទៀតដែលត្រូវបានដាក់ចុះជាផលវិបាកនៃសេចក្តីសម្រេចនេះ នៅមុខអាជ្ញាធរ ឬស្ថាប័នតុលាការមានសមត្ថកិច្ច ឯករាជ្យ មិនលំអៀង ដែលខ្ពស់ជាងបាន ។

ខ-៦- ទទួលបានដោយឥតគិតថ្លៃនូវរាល់ជំនួយអ្នកបកប្រែ បើសិនជាកុមារមិនអាចស្ដាប់ ឬនិយាយភាសា ដែលត្រូវបានប្រើនោះទេ។

ខ-៧- ជីវិតឯកជនរបស់កុមារត្រូវបានគោរពទាំងស្រុង នៅគ្រប់ដំណាក់កាលនៃនីតិវិធី។

៣. រដ្ឋជាភាគីត្រូវស្វះស្វែងជម្រុញការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នទាំងឡាយ ដែលទទួលដោយឡែកលើបញ្ហាកុមារដែលត្រូវសង្ស័យ ចោទប្រកាន់ ឬត្រូវបានទទួលស្គាល់ថាបានប្រព្រឹត្តបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ជាពិសេស :

(ក) កំណត់នូវអាយុអប្បបរមាមួយ ដែលអាយុក្រោមនេះ កុមារត្រូវបានចាត់ទុកថាមិនមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌបាន។

(ខ) បើសិនជាមានលទ្ធភាព និងជាប្រការល្អ ប្រកាន់យកនូវវិធានការទាក់ទិននឹងកុមារប្រភេទនេះ ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីផ្នែកតុលាការ ទន្ទឹមនឹងការធានាថាសិទ្ធិមនុស្សហើយនិងរាល់កិច្ចការធានាផ្នែកផ្លូវច្បាប់ត្រូវបានគោរពទាំងស្រុង។

៤. បទបញ្ញត្តិដ៏ទូលំទូលាយ ដូចជាការថែទាំ ការណែនាំនិងការពិនិត្យគ្រប់គ្រង ការផ្ដល់មតិទូន្មាន ការសាកល្បង ការដាក់ឱ្យរស់នៅតាមគ្រួសារ កម្មវិធីអប់រំទូទៅនិងអប់រំវិជ្ជាជីវៈ ក៏ដូចជាដំណោះស្រាយផ្សេងទៀតជាចំលាស់នឹងការថែទាំនៅតាមស្ថាប័ន ត្រូវបានរៀបចំឡើងដើម្បីធានាថាកុមារត្រូវបានទទួលការថែទាំមួយសមស្របជាមួយនឹងផាសុកភាពរបស់ខ្លួនហើយសមាមាត្ររវាងស្ថានភាពរបស់កុមារនិងទម្ងន់នៃបទល្មើសនោះ។

## មាត្រា ៤១

គ្មានបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះនឹងប៉ះពាល់ដល់បទបញ្ញត្តិផ្សេងៗទៀតដែលផ្ដល់អំណោយផលល្អជាង ដល់ការធ្វើឱ្យមានការអនុវត្តជាក់ស្ដែងនូវសិទ្ធិទាំងឡាយរបស់កុមារ ដែលមានចែងនៅក្នុង:

(ក) ច្បាប់របស់រដ្ឋជាភាគី ឬ

(ខ) ច្បាប់អន្តរជាតិដែលមានជាធរមានចំពោះរដ្ឋនោះ។

## ផ្នែកទី ២

### មាត្រា ៤២

រដ្ឋជាភាគីសន្យាថា នឹងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវគោលការណ៍និងបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ទាំងដល់មនុស្សពេញវ័យ ទាំងដល់កុមារ ដោយប្រើមធ្យោបាយសមស្រប និងជំសកម្ម។

### មាត្រា ៤៣

១. ដើម្បីត្រួតពិនិត្យវឌ្ឍនភាពទាំងឡាយដែលសម្រេចបានដោយរដ្ឋជាភាគី ក្នុងការធ្វើឱ្យចេញជាជាក់ស្តែងនូវកាតព្វកិច្ចនានារបស់ខ្លួនដែលបានសន្យានៅក្នុងអនុសញ្ញានេះ ទាមទារឱ្យមានការបង្កើតឡើងនូវគណៈកម្មាធិការស្តីពីសិទ្ធិកុមារ ដែលមានភារកិច្ចដូចបានកំណត់ខាងក្រោមនេះ។

២. គណៈកម្មាធិការត្រូវមានសមាជិកជាអ្នកឯកទេសចំនួនដប់ប្រាំបីរូប ដែលប្រកបដោយសីលធម៌ខ្ពស់ និងមានការទទួលស្គាល់ពីសមត្ថភាពក្នុងវិស័យដែលជាមុខសញ្ញានៃអនុសញ្ញានេះ។ សមាជិកនៃគណៈកម្មាធិការនេះនឹងត្រូវបានបោះឆ្នោតជ្រើសតាំងឡើងដោយរដ្ឋជាភាគី ក្នុងចំណោមពលរដ្ឋរបស់ខ្លួន និងត្រូវបំពេញការងារក្នុងឋានៈផ្ទាល់ខ្លួននិងដោយយោលទៅលើការបែងចែកសមស្របតាមភូមិសាស្ត្រ ក៏ដូចជាតាមប្រព័ន្ធច្បាប់សំខាន់ៗផងដែរ។

៣. សមាជិកទាំងឡាយនៃគណៈកម្មាធិការ នឹងត្រូវជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតជាសម្ងាត់លើបញ្ជីរាយនាមបេក្ខជន ដែលស្នើឡើងដោយរដ្ឋជាភាគីទាំងឡាយ។ រដ្ឋជាភាគីនីមួយៗអាចស្នើបេក្ខជនបានម្នាក់ក្នុងចំណោមពលរដ្ឋផ្ទាល់របស់ខ្លួន។

៤. ការបោះឆ្នោតជាលើកដំបូងបង្អស់ មិនត្រូវឱ្យយូរលើសពីប្រាំមួយខែក្រោយពីអនុសញ្ញានេះចូលជាធរមានឡើយ ហើយនៅពេលក្រោយៗមកទៀតត្រូវបោះឆ្នោត ជារៀងរាល់ឆ្នាំទីពីរ។ យ៉ាងតិចបំផុតបួនខែមុនដល់ពេលកំណត់នៃការបោះឆ្នោត នីមួយៗ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវផ្ញើលិខិតដល់រដ្ឋជាភាគីទាំងឡាយ ស្នើសុំឱ្យឧទ្ទេសនាមបេក្ខជនរបស់ខ្លួនក្នុងអំឡុងពេលពីរខែ។ បន្ទាប់មក អគ្គលេខាធិការត្រូវរៀបចំបញ្ជី

ឈ្មោះបេក្ខជនដែលបានស្នើឡើងនោះ តាមលំដាប់អក្សរ (បង្ហាញឈ្មោះរដ្ឋជាភាគីដែលបានស្នើឈ្មោះពួកគេផង) និងបញ្ជូនបញ្ជីនេះទៅរដ្ឋជាភាគីទាំងឡាយនៃអនុសញ្ញា។

៥. ការបោះឆ្នោតនឹងត្រូវធ្វើឡើងក្នុងសម័យប្រជុំនៃរដ្ឋជាភាគីទាំងឡាយនៅទីស្នាក់ការអង្គការសហប្រជាជាតិ ដែលត្រូវកោះអញ្ជើញដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។ នៅក្នុងសម័យប្រជុំទាំងនោះ (ដែលទាមទារវត្តមានពីរភាគបីនៃរដ្ឋជាភាគីទើបគ្រប់កូរ៉ុម) អ្នកដែលជាប់ជាសមាជិកនៃគណៈកម្មាធិការ គឺបេក្ខជនណាដែលទទួលបានសម្លេងច្រើនជាងគេបំផុត និងបានសម្លេងភាគច្រើនដាច់ខាតនៃអ្នកតំណាងនៃរដ្ឋជាភាគីដែលមានវត្តមាននៅក្នុងសម័យប្រជុំ និង ដែលបានបោះឆ្នោត។

៦. សមាជិកនៃគណៈកម្មាធិការ នឹងត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំ។ សមាជិកទាំងនេះអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាថ្មីទៀតបាន នៅពេលដែលមានការឧទ្ទេសនាមជាថ្មីទៀត។ អាណត្តិរបស់សមាជិកប្រាំរូបដែលបានជាប់ឆ្នោតក្នុងការបោះឆ្នោតលើកទីមួយនោះនឹងត្រូវបញ្ចប់ក្នុងរយៈពេលពីរឆ្នាំ។ ក្រោយពីការបោះឆ្នោតលើកទីមួយបានចប់សព្វគ្រប់ភ្លាម ឈ្មោះរបស់សមាជិកទាំងប្រាំនាក់នោះនឹងត្រូវប្រធានអង្គប្រជុំជាអ្នកចាប់ឆ្នោត។

៧. បើសិនជាមានសមាជិកនៃគណៈកម្មាធិការទទួលមរណភាព ឬសុំលាលែង ឬដោយសម្អាងលើប្រការណាមួយ ថាខ្លួនមិនអាចបំពេញភារកិច្ចរបស់គណៈកម្មាធិការបានទេនោះ រដ្ឋជាភាគីដែលបានឧទ្ទេសនាមសមាជិកនេះ ត្រូវចាត់តាំងអ្នកឯកទេសម្នាក់ទៀតក្នុងចំណោមពលរដ្ឋខ្លួនឱ្យបំពេញអាណត្តិដែលនៅសល់ក្នុងលក្ខខណ្ឌដែលការចាត់តាំងទទួលបានការយល់ព្រមពីគណៈកម្មាធិការផង។

៨. គណៈកម្មាធិការត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងនិងនីតិវិធីរបស់ខ្លួនផ្ទាល់។

៩. គណៈកម្មាធិការត្រូវជ្រើសតាំងមន្ត្រីផ្លូវការរបស់ខ្លួនសម្រាប់រយៈពេលពីរឆ្នាំ។

១០. ជាធម្មតាសម័យប្រជុំរបស់គណៈកម្មាធិការនឹងត្រូវធ្វើឡើង នៅទីស្នាក់ការនៃអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របណាមួយទៀតអាស្រ័យដោយការកំណត់របស់គណៈកម្មាធិការ។ ជាធម្មតាគណៈកម្មាធិការត្រូវមានការប្រជុំជារៀងរាល់ឆ្នាំ។ រយៈពេលនៃការប្រជុំរបស់គណៈកម្មាធិការនឹងត្រូវកំណត់ ឬបើចាំបាច់ ត្រូវកែប្រែឡើងវិញ ដោយរដ្ឋជា

ភាគីនៃអនុសញ្ញានេះ ក្នុងលក្ខខណ្ឌដែលការសម្រេចនេះទទួលបានការយល់ព្រមពីមហាសន្និបាតនៃអង្គការសហប្រជាជាតិផង ។

១១. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវឧបត្ថម្ភបុគ្គលិក និងឧបករណ៍ប្រើប្រាស់ចាំបាច់ផ្សេងៗ សម្រាប់ឱ្យគណៈកម្មាធិការអាចបំពេញភារកិច្ចរបស់ខ្លួនដែលមាននៅក្នុងអនុសញ្ញានេះប្រកបដោយប្រសិទ្ធភាព ។

១២. ដោយមានការយល់ព្រមពីមហាសន្និបាត សមាជិកនៃគណៈកម្មាធិការដែលត្រូវបានចាត់តាំងឡើងដោយអនុសញ្ញានេះ ត្រូវទទួលបៀវត្សរ៍ពីថវិការបស់អង្គការសហប្រជាជាតិក្នុងកម្រិតនិងលក្ខខណ្ឌដែលមហាសន្និបាតបានសម្រេច ។

## មាត្រា ៤៤

១. តាមរយៈអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ រដ្ឋជាភាគីសន្យាដាក់ជូនគណៈកម្មាធិការនូវរបាយការណ៍ស្តីពីវិធានការនានាដែលខ្លួនបានប្រកាន់យកដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់សិទ្ធិទាំងឡាយដែលបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ និងពីវឌ្ឍនភាពដែលសម្រេចបាននៅក្នុងការឆ្លើយតបទៅនឹងសិទ្ធិទាំងនេះ :

(ក) ក្នុងរយៈពេលពីរឆ្នាំ ក្រោយពីអនុសញ្ញានេះចូលជាធរមាន ចំពោះរដ្ឋជាភាគីដែលពាក់ព័ន្ធ ។

(ខ) បន្ទាប់មកទៀត ជារៀងរាល់ប្រាំឆ្នាំម្តង ។

២. របាយការណ៍ដែលធ្វើឡើងដោយអនុលោមតាមមាត្រានេះ ត្រូវលើកឡើងពីកត្តានិងការលំបាកនានា (បើសិនជាមាន) ដែលជះឥទ្ធិពលដល់ការធ្វើឱ្យបានសម្រេចនូវកាតព្វកិច្ចទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ របាយការណ៍ត្រូវផ្តល់ផងដែរ នូវព័ត៌មានឱ្យបានគ្រប់គ្រាន់ ដើម្បីអាចឱ្យគណៈកម្មាធិការមានការយល់ដឹងគ្រប់ជ្រុងជ្រោយ ស្តីពីការអនុវត្តអនុសញ្ញានេះនៅក្នុងប្រទេសដែលមានការទាក់ទិន ។

៣. រដ្ឋជាភាគីដែលបានដាក់ជូនគណៈកម្មាធិការនូវរបាយការណ៍ដំបូងដែលមានព័ត៌មានគ្រប់គ្រាន់ មិនចាំបាច់(ក្នុងរបាយការណ៍ក្រោយៗទៀត ដោយអនុលោមតាមកថាខ័ណ្ឌ១(ខ) នៃមាត្រានេះ) ផ្តល់ឡើងវិញពីព័ត៌មានជាមូលដ្ឋានដែលបានលើកឡើងពីលើកមុនៗនោះឡើយ ។

៤. គណៈកម្មាធិការអាចស្នើសុំដល់រដ្ឋជាភាគី នូវព័ត៌មានបន្ថែមផ្សេងៗទៀតទាក់ទិននឹងការអនុវត្តអនុសញ្ញានេះ ។

៥. តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម គណៈកម្មាធិការត្រូវដាក់របាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួនជូនដល់មហាសន្និបាត ជារៀងរាល់ពីរឆ្នាំម្តង ។

៦. រដ្ឋជាភាគីត្រូវផ្សព្វផ្សាយរបាយការណ៍របស់ខ្លួន ឱ្យបានទូលំទូលាយនៅក្នុងប្រទេស ។

## មាត្រា ៤៥

ដើម្បីជម្រុញការអនុវត្តអនុសញ្ញានេះប្រកបដោយប្រសិទ្ធភាព និងដើម្បីលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការជាអន្តរជាតិ នៅក្នុងវិស័យដែលជាមុខសញ្ញានៃអនុសញ្ញានេះ ៖

(ក) ទីភ្នាក់ងារឯកទេស មូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ និងរាល់ស្ថាប័ននានានៃអង្គការសហប្រជាជាតិ មានសិទ្ធិចាត់តាំងតំណាងខ្លួនឱ្យចូលរួមក្នុងការត្រួតពិនិត្យការអនុវត្តបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ដែលទាក់ទិននឹងមុខការរបស់ខ្លួន ។ គណៈកម្មាធិការអាចអញ្ជើញទីភ្នាក់ងារឯកទេសមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ និងស្ថាប័នមានសមត្ថកិច្ចផ្សេងៗទៀតដែលខ្លួនយល់ថាសមស្រប ដើម្បីផ្តល់មតិឯកទេសស្តីពីការអនុវត្តអនុសញ្ញានេះ នៅក្នុងវិស័យដែលទាក់ទិនទៅនឹងមុខការរបស់ខ្លួនផ្ទាល់ ។ គណៈកម្មាធិការអាចអញ្ជើញទីភ្នាក់ងារឯកទេសមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ និងស្ថាប័នផ្សេងៗទៀតរបស់អង្គការសហប្រជាជាតិ ឱ្យដាក់ជូនខ្លួននូវរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញានេះនៅក្នុងវិស័យទាំងឡាយ ដែលទាក់ទិនទៅនឹងដែនសកម្មភាពរបស់ស្ថាប័នទាំងនោះ ។

(ខ) នៅពេលដែលយល់ថាចាំបាច់ គណៈកម្មាធិការត្រូវផ្តល់ជូនដល់ទីភ្នាក់ងារឯកទេសមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារនិងស្ថាប័នមានសមត្ថកិច្ចឯទៀតនូវរបាយការណ៍របស់រដ្ឋជាភាគីណាដែលមានសំណើសុំ ឬបង្ហាញថាមានតម្រូវការស្តីពីមតិណែនាំ ឬជំនួយឧបត្ថម្ភផ្នែកបច្ចេកទេសនានា ហើយបើសិនជាមាន ភ្ជាប់ជាមួយនូវសេចក្តីសង្កេត និងសំណើនានារបស់គណៈកម្មាធិការ តាមការស្នើសុំ ឬការចង្អុលបង្ហាញទាំងនេះ ។

(ឥ) គណៈកម្មាធិការអាចផ្ដល់អនុសាសន៍ដល់មហាសន្និបាត ដើម្បីស្នើសុំឱ្យអគ្គលេខាធិការចាត់ចែងក្នុងនាមគណៈកម្មាធិការ ដាក់ឱ្យមានជាការសិក្សាស្រាវជ្រាវលើបញ្ហាជាក់លាក់ ដែលទាក់ទិនដល់កុមារ ។

(ឃ) គណៈកម្មាធិការអាចលើកជាសំណើនិងអនុសាសន៍ជាទូទៅ ដោយផ្អែកលើព័ត៌មានដែលបានទទួល អនុលោមទៅតាមមាត្រា៤៤និង៤៥នៃអនុសញ្ញានេះ ។ សំណើនិងអនុសាសន៍ជាទូទៅទាំងនេះ ត្រូវបញ្ជូនទៅរាល់រដ្ឋជាភាគីដែលទាក់ទិននិងរាយការណ៍ជូនដល់មហាសន្និបាត ហើយបើសិនជាមាន ដោយភ្ជាប់ជាមួយនូវមតិយោបល់របស់រដ្ឋជាភាគីផង ។

## ផ្នែកទី ៣

### មាត្រា ៤៦

អនុសញ្ញានេះ ត្រូវបានបើកចំហសម្រាប់គ្រប់រដ្ឋទាំងអស់ចុះហត្ថលេខា ។

### មាត្រា ៤៧

អនុសញ្ញានេះតម្រូវឱ្យមានការផ្ដល់សច្ចាប័ន ។ ឯកសារនៃការឱ្យសច្ចាប័នត្រូវតម្កល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

### មាត្រា ៤៨

អនុសញ្ញានេះ បើកឱ្យមានការចូលរួមពីគ្រប់រដ្ឋទាំងអស់ ។ ឯកសារស្ដីពីការចូលរួមនឹងត្រូវតម្កល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

### មាត្រា ៤៩

១. អនុសញ្ញានេះ នឹងចូលជាធរមានសាមសិបថ្ងៃក្រោយពីឯកសារឱ្យសច្ចាប័ន ឬឯកសារសុំចូលរួមទីម្ភៃត្រូវបានតម្កល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិនោះមក ។

២. ចំពោះរដ្ឋនីមួយៗដែលបានឱ្យសច្ចាប័នឬដែលបានចូលរួមក្នុងអនុសញ្ញា ក្រោយពីឯកសារនៃការឱ្យសច្ចាប័នឬឯកសារនៃការចូលរួមទីម្ភៃត្រូវបានតម្កល់ទុកហើយនោះ អនុសញ្ញានេះនឹងចូលជាធរមាននៅសាមសិបថ្ងៃក្រោយពីថ្ងៃដែលឯកសារឱ្យសច្ចាប័ន ឬការចូលរួមរបស់រដ្ឋនោះត្រូវបានតម្កល់ទុកហើយ ។

### មាត្រា ៥០

១. គ្រប់រដ្ឋជាភាគីទាំងអស់អាចស្នើវិសោធនកម្ម ហើយដាក់សំណើនេះទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការត្រូវបញ្ជូនសំណើវិសោធនកម្មនេះ ទៅរដ្ឋជាភាគីទាំងឡាយ ដោយស្នើសុំឱ្យរដ្ឋជាភាគីទាំងនោះ ផ្ដល់ដំណឹងមកដល់ខ្លួនវិញថា តើគាំទ្រឱ្យមានការកោះប្រជុំសន្និសីទនៃរដ្ឋជាភាគីដើម្បីពិនិត្យនិងបោះឆ្នោតលើសំណើនេះឬទេ ។ បើសិនជានៅក្នុងរយៈពេលបួនខែក្រោយពីការជូនដំណឹងនេះ មានមួយភាគបីយ៉ាងតិចនៃរដ្ឋជាភាគីទាំងឡាយបានគាំទ្រសន្និសីទប្រភេទនេះ ពេលនោះអគ្គលេខាធិការត្រូវកោះប្រជុំក្រោមការចាត់ចែងរបស់អង្គការសហប្រជាជាតិ ។ រាល់វិសោធនកម្មដែលត្រូវបានអនុម័តដោយសម្លេងភាគច្រើននៃរដ្ឋជាភាគីដែលមានវត្តមាន និងដែលបានបោះឆ្នោតនៅក្នុងសន្និសីទនោះ ត្រូវដាក់សុំមតិឯកភាពពីមហាសន្និបាត ។

២. រាល់វិសោធនកម្មដែលត្រូវបានអនុម័តដូចមានចែងនៅក្នុងកថាខ័ណ្ឌ១នៃមាត្រានេះនឹងចូលជាធរមាននៅពេលដែលបានការឯកភាពពីមហាសន្និបាតនៃអង្គការសហប្រជាជាតិ និងទទួលយកដោយសម្លេងភាគច្រើនពីរភាគបីនៃរដ្ឋជាភាគី ។

៣. នៅពេលដែលវិសោធនកម្មចូលជាធរមាន វិសោធនកម្មនេះមានអនុភាពជាកំហិតទៅលើរដ្ឋជាភាគីទាំងឡាយដែលបានទទួលយក រដ្ឋជាភាគីផ្សេងទៀតស្ថិតនៅក្រោមអនុភាពនៃបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះហើយនិងរាល់វិសោធនកម្មមុនៗដែលខ្លួនបានទទួលយកតែប៉ុណ្ណោះ ។

## មាត្រា ៥១

១. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវទទួលនិងបញ្ជូនទៅគ្រប់រដ្ឋទាំងអស់នូវអត្ថបទនៃការដាក់លក្ខខណ្ឌរបស់រដ្ឋនានា ដែលបានធ្វើឡើងនៅពេលឱ្យសច្ចាប័ន ឬនៅពេលសុំចូលរួមនោះ ។

២. ការដាក់លក្ខខណ្ឌណាមួយដែលផ្ទុយនឹងកម្មវត្ថុ និងគោលដៅនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតឡើយ ។

៣. ការដាក់លក្ខខណ្ឌនេះ អាចដកវិញបាននៅគ្រប់ពេលវេលា ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីបញ្ហានេះដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែលបន្ទាប់មកនឹងជូនដំណឹងដល់រដ្ឋឯទៀតៗ ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរ នឹងមានប្រសិទ្ធភាពនៅថ្ងៃដែលអគ្គលេខាធិការបានទទួល ។

## មាត្រា ៥២

រដ្ឋជាភាគីអាចសុំដកខ្លួនចេញពីអនុសញ្ញានេះបាន ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។ ការសុំចេញនេះនឹងមានប្រសិទ្ធភាពមួយឆ្នាំក្រោយពីពេលដែលអគ្គលេខាធិការបានទទួលការជូនដំណឹងនេះ ។

## មាត្រា ៥៣

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវបានចាត់តាំងជាអ្នកទទួលរក្សាទុកអនុសញ្ញានេះ ។

## មាត្រា ៥៤

ច្បាប់ដើមនៃអនុសញ្ញាដែលមានអត្ថបទជាភាសាអារ៉ាប់ ភាសាចិន ភាសាអង់គ្លេស ភាសាបារាំង ភាសារុស្ស៊ី និង ភាសាអេស្ប៉ាញនេះ មានតម្លៃស្មើគ្នា និងត្រូវតម្កល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

ជាកសិណនៃកិច្ចនេះ ភាគីហត្ថលេខីខាងក្រោមដែលបានទទួលការអនុញ្ញាតយ៉ាងពេញលេញពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខានៅលើអនុសញ្ញានេះ ។



កម្មវិធីពិភាក្សាតុមូល
ស្តីពីសិទ្ធិកុមារ
មណ្ឌលសុខភាព
ចេញ